ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- សិក្សាប្រវត្តិសាស្ត្រ គឺមានសារសំខាន់ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅលើពិភពលោកនាពេលអនាគត
- ក្រសួងមហាផ្ទៃផ្ដល់ការអនុញ្ញាត និងកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការផ្សព្វផ្សាយកូនសៀវភៅអំពីសុខភាព និងផ្ទាំងរូបភាពសុខភាព ជូនប្រជាពលរដ្ឋ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៦ ខែតុលា ឆ្នាំ២០២៣

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៦ ខែកញ្ញា ឆ្នាំ២០២៣



យុទ្ធជន និងយុទ្ធនារីនៃកងទ័ពបដិវត្តន៍ខ្មែរក្រហមកំពុងស្ទូងនៅវាលស្រែ ក្នុងនៅតំបន់រំដោះ នៅក្នុងឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


◆ សិក្សាប្រវត្តិសាស្ត្រ គឺមានសារសំខាន់ ......... ១
◆ សិទ្ធិក្នុងការរស់រានមានជីវិតនាយុគសម័យ ..... ៤


### ផ្នែកឯកសារ


◆ វ៉ែន វ៉ន ហៅ វង់ ម៉ន អនុលេខាវរសេនាតូច...... ៨


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ក្រសួងមហាផ្ទៃផ្ដល់ការអនុញ្ញាត និងកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ............ ១១
◆ ចំណុះទូករមាជើងព្រៃ ស្រុកជើងព្រៃ ......... ១៣
◆ មេឃុំព្រៃផ្ដៅ ចាន់ អិន រំឭកអំពីអនុស្សាវរីយ៍.. ១៥
◆ សិស្សានុសិស្សចំនួន១៥០នាក់ នៃវិទ្យាល័យសម្ដេចតេជោ ហ៊ុន សែន សង្កើប ទទួលបានសៀវភៅ... ១៩
◆ មជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ .............. ២១
◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ............ ២៤
◆ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ ........... ២៦
◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សាស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជា... ២៩
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំកម្មវិធីទស្សនកិច្ចសិក្សាស្ដីអំពី«សន្តិភាព និងសិទ្ធិមនុស្ស»... ៣២
◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ជួបប្រជុំពិភាក្សាជាមួយអភិបាល និងអភិបាលរង ... ៣៥
◆ វគ្គបណ្ដុះបណ្ដាលអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ .. ៣៨
◆ ការពង្រឹងភាពជាអ្នកដឹកនាំក្នុងដំណើរការសកម្មភាពការងារជាមួយអ្នករស់រានមានជីវិតពីរបប.... ៣៧
◆ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិទី១០ ................................ ៤០


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


◆ មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ... ៤៣
◆ សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ចារថ្មី ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពីសារសំខាន់នៃ.......... ៤៥
◆ សិស្សវិទ្យាល័យក្រាំងស្វាត ចូលរួមវេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីអំពី«ប្រវត្តិសាស្ត្រកម្ពុជា ....... ៤៨
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្ដីអំពី«ប្រវត្តិសាស្ត្រកម្ពុជា ............. ៥៣
◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនស្ដីអំពីសារសំខាន់នៃការសិក្សា .......... ៥៦
◆ វេទិកាអប់រំសហគមន៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ....... ៥៨
◆ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ..... ៥៨


### ផ្នែកស្រាវជ្រាវរកក្រួសារ


◆ អាន គុម ៖ ខ្ញុំបាត់បង់បងប្រុសម្នាក់............ ៦១



**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ១៣៧ ៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, មីន សាណាស់, សោម ប៊ុនថន, លី ដេវីត, ដេង ពង្សរ៉ាស៊ី, ទូច វណ្ណេត, វី ស៊ីថា, ចាន់ ណារិទ្ធ, ធី គីមហុង, សាំង ចាន់ធូ, មេក វិន, ជុន ស្រីពេជ្រ, សុភ័ក្ត្រ ភាណា, ឈុំ រ៉ា, រឹម ស្រីស្រស់, ង៉ាន់ វីន, សួត វិចិត្រ, ធី គីមហុង និង ផន វន្នី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ុកភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# សិក្សាប្រវត្តិសាស្ត្រ គឺមានសារសំខាន់ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅលើ ពិភពលោកនាពេលអនាគត

**ឆាំង យុ**



*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

យើងអាចនិយាយបានថា លទ្ធិប្រជាធិបតេយ្យគឺជាកម្លាំងដែលមិនចេះចុះញ៉មនៅក្នុងប្រវត្តិសាស្ត្រ។ ក្នុងនាមសេរីភាព និងសមភាព លទ្ធិប្រជាធិបតេយ្យលើកកម្ពស់ដល់សំឡេងរបស់មនុស្សប្រុសស្រី និងបំបែកប្រព័ន្ធនយោបាយបែបឋានានុក្រមៗ ដូចគ្នាទៅនឹងលទ្ធិប្រជាធិបតេយ្យដែរ ការអប់រំនាំមកនូវសក្តានុពលប្រកបដោយថាមពលក្នុងការកែប្រែសង្គមៗ ការអប់រំដែលផ្តោតលើការត្រិះរិះពិចារណា ការឆ្លុះបញ្ចាំងអំពីខ្លួនឯង និងសេចក្តីអាណិតអាសូរ អាចបង្កើតជាផ្នត់គំនិតថ្មីៗជាលក្ខណៈបុគ្គល និងជារួម ដើម្បីបង្ហាញពីការយល់ឃើញ និងផ្តល់ដល់មនុស្សនូវឧបករណ៍ក្នុងការចោទសួរខ្លួនឯង ស្ថាប័ន និងពិភពលោកៗ ដូចគ្នាទៅនឹងលទ្ធិប្រជាធិបតេយ្យដែរ ការអប់រំក៏អាចជាអំណាចដ៏វិសេសវិសាលរបស់មនុស្សជាតិក្នុងការសម្រេចបាននូវសន្តិភាព សេរីភាព និងយុត្តិធម៌ៗ

ការសិក្សាអំពីប្រវត្តិសាស្ត្រ គឺជាសមាសធាតុសំខាន់សម្រាប់ចក្ខុវិស័យនៃការអប់រំៗ ប្រវត្តិសាស្ត្រអាចត្រូវបានសិក្សាដើម្បីបណ្តុះការយល់ដឹង និង

ឆ្លុះបញ្ចាំងប្រកបដោយការត្រិះរិះពិចារណា តាមរយៈគំនិតពីអតីតកាល ពីមនុស្ស និងពីស្ថាប័នៗ ប្រវត្តិសាស្ត្រ អាចជាមូលដ្ឋានគ្រឹះនៃក្ដីសង្ឃឹម ការលើកទឹកចិត្ត និងការសណ្ដោសប្រណី។ ទន្ទឹមនឹងនេះដែរ ប្រវត្តិសាស្ត្រក៏អាចត្រូវបានប្រើប្រាស់ជាសម្ភារសម្រាប់ការអប់រំ ដើម្បីពន្យល់អំពីកំហុស គុណវិបត្តិ និងអំពើខុសឆ្គងនៅក្នុងសង្គម។ ប្រវត្តិសាស្ត្រ ជំរុញឲ្យសង្គមទទួលស្គាល់ទុក្ខវេទនាដែលបង្កឡើងដោយសាសនា វប្បធម៌ និងប្រទេសជាតិ។ ប្រវត្តិសាស្ត្រ ជំរុញឲ្យបុគ្គលហ៊ានប្រឈមមុខនឹងភាពភ័យខ្លាចដែលកើតមានឡើងនៅក្នុងសង្គម។

ដោយសារតែអំណាចដ៏មហិមានៃប្រវត្តិសាស្ត្រក្នុងការបង្កើតអត្តសញ្ញាណ វប្បធម៌ និងចក្ខុវិស័យបែបសហសម័យ យើងត្រូវតែធ្វើឲ្យការសិក្សាអំពីប្រវត្តិសាស្ត្រ ប្រែទៅជាសមាសធាតុដ៏មានសារសំខាន់សម្រាប់យុទ្ធសាស្ត្រជាសកល ក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ ទោះបីជាបញ្ហាជាសកលតម្រូវឲ្យមានយុទ្ធសាស្ត្រជាសកលក្នុងការដោះស្រាយយ៉ាងណាក៏ដោយ ក៏យុទ្ធសាស្ត្រទាំងនេះត្រូវពឹងផ្អែកលើការចូលរួមពីថ្នាក់មូលដ្ឋានដែលមិនអាចខ្វះបានទាល់តែសោះ។

យុទ្ធសាស្ត្រជាសកលនានា ដែលត្រូវបានប្រើប្រាស់សម្រាប់បង្ការ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ គឺពិតជាចាំបាច់ក្នុងការកំណត់លក្ខខណ្ឌ និងឱកាសទូទៅសម្រាប់កិច្ចសហប្រតិបត្តិការ និងការធ្វើការរួមគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែពិភពលោកនៅក្នុងយុគសម័យសកលភាវូបនីយកម្មក្ដី ក៏រាល់បញ្ហា និងដំណោះស្រាយ ទាំងអស់ត្រូវកើតចេញពីការផ្ដួចផ្ដើមនៅតាមបណ្ដាភូមិឃុំ។ ប្រសិនបើយើងទទួលស្គាល់ថាមនុស្សគ្រប់រូបមានសក្ដានុពលដើម្បីផ្លាស់ប្ដូរ បុគ្គលនិងសហគមន៍នោះនឹងដើរតួនាទីជាផ្នែកយ៉ាងសំខាន់មួយនៃយុទ្ធសាស្ត្រសកលលោក។ ទោះជាមានធនធានប៉ុន្មានក៏ដោយ ជោគជ័យនៃយុទ្ធសាស្ត្រជាសកលនឹងអាស្រ័យទៅលើការចូលរួម ការដឹកនាំ និងភាពជាម្ចាស់ការរបស់សហគមន៍ក្នុងភូមិឃុំ។ ភាពជាម្ចាស់ការក្នុងភូមិឃុំលើយុទ្ធសាស្ត្រនានា ពុំមែនមានន័យថា សហគមន៍ក្នុងភូមិឃុំអាច ឬគួរតែដោះស្រាយបញ្ហារបស់ខ្លួនដោយខ្លួនឯងនោះទេ។ ការណែនាំផ្លូវ ការគាំពារ ការអប់រំ និងគោលគំនិត គឺសុទ្ធសឹងតែជាផ្នែកដ៏សំខាន់ដែលសហគមន៍អន្តរជាតិអាចចូលរួមចំណែកដើម្បីលើកកម្ពស់និងជួយដល់បុគ្គលក៏ដូចជាស្ថាប័នមូលដ្ឋានឲ្យចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ ប្រវត្តិសាស្ត្រ គឺមិនត្រឹមតែពឹងផ្អែកលើការផ្ដល់ពេលវេលា ឬជួយមនុស្សតែប៉ុណ្ណោះទេ។ យើងត្រូវតែចំណាយធនធានលើប្រតិបត្តិការ និងសម្ភារឧបទេស ព្រោះថាគ្រូបង្រៀនល្អ គឺត្រូវពឹងផ្អែកលើបរិយាកាសសិក្សាដែលមានប្រភពធនធានល្អៗគ្រប់គ្រាន់។

កម្មវិធីសិក្សាគ្រប់ជ្រុងជ្រោយស្ដីពីការសម្លាប់រង្គាលផ្សេងៗនៅក្នុងប្រវត្តិសាស្ត្រ គឺជាការចូលរួមចំណែកតូចមួយចំពោះការតស៊ូកម្រិតមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ ទោះបីជាប្រទេសកម្ពុជាបានបោះជំហានយ៉ាងសំខាន់ក្នុងការបង្រៀនប្រវត្តិសាស្ត្ររបស់ខ្លួននៅតាមបណ្ដាសាលារៀន និងសហគមន៍អាទិភាពយ៉ាងណាក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវសម្រេចឲ្យបាន ក្នុងការអប់រំមនុស្សជំនាន់ក្រោយពីអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងអំពើហិង្សាជ្រុលហួសហេតុ។ កម្មវិធីសិក្សានេះ មានគោលបំណងបំពេញចន្លោះខ្វះខាតទាំងអស់ តាមរយៈការផ្ដល់ជារូបភាព និងឧទាហរណ៍នៃបទពិសោធន៍នៅក្នុងសង្គមដទៃទៀតទាក់ទងនឹងការសម្លាប់រង្គាលនានា។ កម្មវិធីសិក្សានេះ ផ្ដល់ដល់អ្នកអប់រំនូវប្រភពធនធានជាច្រើន ដើម្បីបង្កើនការយល់ដឹងរបស់សិស្សអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងជំរុញឲ្យមានការពិភាក្សាដេញដោលពីបទពិសោធន៍របស់ប្រទេសកម្ពុជា

ជាមួយនឹងការសម្លាប់រង្គាលក្នុងប្រទេសនានា ថាតើការសម្លាប់រង្គាល ទាំងអស់មានភាពដូចគ្នានិង ខុសគ្នាយ៉ាងដូចម្តេចខ្លះ។

សង្គមទាំងអស់តម្រូវឲ្យមានកម្មវិធីសិក្សាដែលទាក់ទាញចំណាប់អារម្មណ៍ និងជំរុញឲ្យមានការផ្លាស់ប្តូរ ព្រោះថាគោលបំណងចម្បងនៃការអប់រំ គឺមិនត្រឹមតែបង្ហាញឲ្យឃើញពីការសិក្សារបស់សិស្សតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជជែកវែកញែកអំពីការគិតទុកជាមុន និងការស្វែងយល់អំពីព័ត៌មាន និងគំនិតថ្មីៗទៀត។ ប្រជាជនកម្ពុជាអាចអះអាងអំពីសារសំខាន់នៃការរិះគិតដែលជំរុញឲ្យមានការផ្លាស់ប្តូរ។ ប៉ុន្តែជាទូទៅ សកម្មភាពនិងគំនិតទាំងនេះរបស់ប្រជាជនកម្ពុជា តែងតែត្រូវបានផ្តុកទៅដោយក្តីប្រាថ្នាយ៉ាងជ្រាលជ្រៅចង់បានសន្តិសុខជាអាទិភាពមានប្រៀបជាង ការជំរុញទឹកចិត្ត និងនវានុវត្តភាពទៅវិញ។ ទំនើបភាវូបនីយកម្ម និងភាពច្នៃប្រតិដ្ឋ គឺអាស្រ័យលើអ្នកដឹកនាំ ហើយយើងចាំបាច់ត្រូវតែធ្វើឲ្យប្រសើរឡើងនូវវិធី ដែលអាចលើកកម្ពស់ការពិចារណាដោយអង់អាច និងភាពប៉ិនប្រសព្វ។

កម្មវិធីសិក្សានេះ គឺជាកម្មវិធីសិក្សាខ្លីមួយ ព្រោះថាជួនកាលជំហានតូចៗ ក៏អាចមានឥទ្ធិពលជាងជំហានធំៗបានដែរ។ ជាចុងក្រោយ យើងរំពឹងថាកម្មវិធីសិក្សានេះ នឹងក្លាយជាផ្នែកតូចមួយដើម្បីបំពេញបន្ថែមទៅលើសកម្មភាពផ្សេងៗ សម្រាប់អភិវឌ្ឍន៍ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រដល់មនុស្សជំនាន់ក្រោយ។ គ្មានអ្វីគួរឲ្យមន្ទិលទៀតទេថា ប្រវត្តិ-សាស្ត្រដើរតួនាទីជាវេទិកាដ៏សំខាន់មួយ សម្រាប់ឈានទៅបង្កើតវប្បធម៌មួយដែលគោរព និងការពារលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការអភិវឌ្ឍន៍។

សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀនស្តីអំពី«សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រីនរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិទ្ធិក្នុងការរស់រានមានជីវិតនាយុគសម័យសន្តិភាពនៅក្នុងប្រទេសកម្ពុជា

ឆាំង យុ



ចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានដឹកនាំប្រទេសកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងសោកនាដកម្ម ដែលបណ្ដាលឲ្យប្រជាជនកម្ពុជាជាង២លាននាក់ បានស្លាប់បាត់បង់ជីវិត។ ថ្វីត្បិតតែប្រជាជនកម្ពុជាប្រមាណជាង២លាននាក់ ត្រូវបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមយ៉ាងណាក្ដី ក៏នៅមានអ្នករស់រានមានជីវិតពីរបបនេះប្រមាណជាង៥លាននាក់ទៀត បន្តរៀបរាប់រឿងរ៉ាវជីវិតរបស់ខ្លួន។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កុមារកម្ពុជារាប់សែននាក់ត្រូវបន្សល់ទុកឲ្យនៅកំព្រា។
(រូបភាព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។)

ស្របពេលដែលយើងឈានចូលមកកាន់ខួបអនុស្សាវរីយ៍លើកទី៣២ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ខ្ញុំបាននឹករំពៃដល់គោលការណ៍ជាសកលដ៏សំខាន់ ដែលបានជំរុញឲ្យមានការបិទបញ្ចប់ជម្លោះផ្ទៃក្នុងដ៏យូរអង្វែងជាងមួយទសវត្សរ៍ ...

សិទ្ធិក្នុងការរស់រានមានជីវិត គឺជាសិទ្ធិដំបូងបង្អស់មួយក្នុងចំណោមសិទ្ធិទាំងអស់របស់មនុស្ស ដែលមានតួនាទីចាំបាច់បំផុត ដើម្បីទទួលបានសិទ្ធិមនុស្សដែលមានចែងដទៃទៀត ព្រមទាំងភ្ជាប់ទៅលើសិទ្ធិដទៃទៀតដែរ។ សិទ្ធិនេះ ត្រូវតែទទួលបានការការពារដោយច្បាប់ ហើយគ្មាននរណាម្នាក់ត្រូវទទួលរងការបំពានលើអាយុជីវិតរបស់ខ្លួនឡើយ។

សិទ្ធិក្នុងការរស់រានមានជីវិត គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ក្នុងការដោះស្រាយរាល់ជម្លោះទាំងអស់ ប៉ុន្តែសិទ្ធិនេះតែងត្រូវបានមើលរំលង។ ប្រសិនបើយើងអង្កេតមើលលើជម្លោះទាំងអស់ (ឬលក្ខខណ្ឌនានារុញច្រានឲ្យជម្លោះកើតមានឡើង) ផ្អែកលើផ្នត់គំនិតមួយដែលថា បុគ្គលនីមួយៗ មានសិទ្ធិរស់នៅជីវិតមួយ រួចផុតពីទង្វើនិងការប្រមាថដោយចេតនា ឬប៉ុនប៉ងបង្កឲ្យមានការស្លាប់ខុសពីប្រក្រតីមុនពេលកំណត់ ឬដោយចេតនា ហើយមនុស្សគ្រប់រូបមានសិទ្ធិរស់នៅជីវិតមួយប្រកបដោយកិត្តិយស នោះយើងអាចយល់ដឹងបានកាន់តែច្បាស់អំពីគោលគំនិតស្តីពីសកម្មភាពប្រព្រឹត្តឡើងដោយបុគ្គល, ប្រទេស ឬក្រុមមនុស្សនីមួយៗ ថាតើមានលក្ខណៈត្រឹមត្រូវ (ឬមិនត្រឹមត្រូវ) ក្នុងការឈានទៅសម្រេចបានសុវត្ថិភាព, សេរីភាព, យុត្តិធម៌ និងភាពថ្កុំថ្កើនរបស់ខ្លួន។

ការវាយប្រហារយ៉ាងឃោរឃៅលើជនជាតិអ៊ីស្រាអែល បានសបញ្ជាក់អំពីសារសំខាន់នៃការការពារសិទ្ធិក្នុងការរស់រានមានជីវិត ដោយមិនត្រឹមតែចំពោះប្រជាជនស្លូតត្រង់ ដែលបាត់បង់ជីវិតនៅក្នុងប្រទេសអ៊ីស្រាអែលតែប៉ុណ្ណោះទេ។ រដ្ឋត្រូវតែធានាថា ការឆ្លើយតបចំពោះការវាយប្រហារដ៏ធ្ងន់ធ្ងរ គឺត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីការពារអាយុជីវិតបុគ្គល ដែលពុំបានចូលរួមនៅក្នុងអំពើហិង្សានេះ។ ជម្លោះអាចបង្កពីសភាវគតិរបស់យើង ក៏ប៉ុន្តែនេះមិនមែនមានន័យថា យើងមិនអាចរស់នៅដោយសន្តិភាពនោះទេ។ ជាការពិតណាស់ ក្នុងកាលៈទេសៈខ្លះ ច្រកចេញតែមួយ ឈានទៅសម្រេចបានសន្តិភាព គឺការធ្វើសង្គ្រាម។ បន្ថែមលើពីនេះទៅទៀត រដ្ឋនានាត្រូវដាក់ចេញវិធានការដែលដោះស្រាយចំពោះឫសគល់បង្កជាអំពើហិង្សាដោយមិនមែនប្រកាន់ខ្ជាប់គោលគំនិតក្នុងការកម្ទេចអ្នកបង្កអំពើហិង្សាទេ ក៏ប៉ុន្តែប្រកាន់គោលគំនិតក្នុងការបង្កើតឡើងជាថ្មីនូវស្ថានភាពនានា ដើម្បីផ្តល់ឱកាសដល់វប្បធម៌មួយ ដែលផ្តល់តម្លៃចំពោះសិទ្ធិជាសកលក្នុងការរស់រានមានជីវិត សម្រាប់មនុស្សគ្រប់ៗរូប។

ប្រសិនបើយើងទទួលស្គាល់ថា មនុស្សជាតិទាំងអស់ មានឥទ្ធិពលក្នុងការបញ្ចប់ជម្លោះនៅជុំវិញពិភពលោក មិនថានៅទីតាំងឆ្ងាយ ឬអ្នកមានទំនោរខុសពីយើង នោះយើងនឹងអាចសង្កេតឃើញថា ពិភពលោកទាំងមូលមានតួនាទីយ៉ាងចាំបាច់ក្នុងជម្លោះនៅមជ្ឈិមបូព៌ា, សង្គ្រាមក្នុងប្រទេសអ៊ុយក្រែន និងនៅគ្រប់ទីតាំងទាំងអស់ដែលមានវត្តមានសង្គ្រាម និងអស្ថិរភាព។ ដើម្បីទទួលស្គាល់ពីឥទ្ធិពលនៃមនុស្សជាតិក្នុងការបញ្ចប់ជម្លោះ នៅជុំវិញពិភពលោក យើងត្រូវតែសកម្មក្នុងការផ្តួចផ្តើម, មោះមុតឆ្ពោះទៅមុខ និងយកចិត្តទុកដាក់យ៉ាងមធ្យ័តចំពោះស្ថានភាពនិងកត្តាជំរុញនានា ដែលរុញច្រានបង្កើតជាជម្លោះ។ ក្នុងន័យនេះ សិទ្ធិក្នុងការរស់រានមានជីវិត គឺមិនមែនត្រឹមតែជាសិទ្ធិជាមូលដ្ឋាន ដែលជំរុញឲ្យមានការបញ្ចប់ជម្លោះប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជាមធ្យោបាយដែលប្រសើរជាងការអប់រំទៅទៀតក្នុងការបង្កើត, ពង្រឹង និងរក្សានូវភាពឋិតថេរចីរកាលនៃវប្បធម៌មួយ ដែលគោរពចំពោះសិទ្ធិក្នុងការរស់រានមានជីវិត។ ការអប់រំផ្តោតលើការយល់ដឹងរបស់មនុស្សជាតិចំពោះកំហុសពីអតីតកាល និងបើកបង្អួចនៃឱកាសថ្មីមួយឆ្ពោះទៅកាន់អនាគត។ ជាក់ស្តែង ការអប់រំពុំអាចជាឱសថព្យាបាលរាល់ជម្លោះកើតមានពីអតីតកាល, នាបច្ចុប្បន្នកាល និងនាអនាគតកាលទាំងអស់បានក៏ពិតមែន ហើយការអប់រំក៏មិនមែនជាការឆ្លើយតបចំពោះរាល់ស្ថានភាពទាំងអស់ ដែលបញ្ឆេះនូវ

ជម្លោះដែរ។ ក៏ប៉ុន្តែ ការអប់រំ តែងត្រូវបានមើលរំលង និងមិនសូវទទួលបានការគាំទ្រទទួលស្គាល់ថាជា ឧបករណ៍ជាយុទ្ធសាស្ត្រក្នុងការរារាំងជម្លោះទេ ហើយដោយគ្មានមន្ទិលសង្ស័យ ការអប់រំទាមទារនូវធនធាន និងការប្តេជ្ញាប្រសើរជាងនេះ។ ជារួម ប្រសិនបើពុំមានការប្តេជ្ញាធ្វើការសិក្សាស្រាវជ្រាវ, ធ្វើការអប់រំ និងធ្វើការតស៊ូមតិអំពីប្រវត្តិសាស្ត្រទេនោះ ប្រវត្តិសាស្ត្រ នឹងក្លាយជាឧបករណ៍ឃោសនានយោបាយជាក់ជាមិនខាន។ នៅពេលដែលសន្តិភាពឬប្រវត្តិសាស្ត្រ ក្លាយជាប្រធានបទនៃការឃោសនា យើងនឹងប្រឈមទៅនឹងការគំរាមកំហែង, ភាពអសន្តិសុខ និងអនាគតដ៏គ្រោះថ្នាក់។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានចំណាយរយៈកាលជាងពីរទសវត្សរ៍កន្លងមកហើយ ក្នុងការខិតខំប្រឹងប្រែងអប់រំពីអំពើប្រល័យពូជសាសន៍ និងសន្តិភាព ក៏ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជា ពុំបានចាប់ផ្តើមកិច្ចការទាំងនេះ ក្នុងនាមជាស្ថាប័នអប់រំទេ។ ការអប់រំ ទាមទារនូវការពិត ចំណែកឯការពិត ទាមទារនូវការប្តេជ្ញាចិត្តឥតរួញរាក្នុងការស្វែងរកការពិត, ការចងក្រងឯកសារ និងការស៊ើបសួរ។ ជំនាញក្នុងការចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាដើមទុនសម្រាប់អភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួននៅក្នុងការអប់រំ។ តម្កល់ទុកនូវបណ្ណសារឯកសារស្តីពីរបបខ្មែរក្រហមដ៏ធំបំផុត មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតជាកម្មវិធីសិក្សា ដែលមិនត្រឹមតែរួមបញ្ចូលឯកសារ និងវត្ថុតាងពាក់ព័ន្ធនឹងរបបខ្មែរក្រហមប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងគួបផ្សំនូវរឿងរ៉ាវជីវិតផ្ទាល់ខ្លួនរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែមទៀតផង។ សាច់រឿងទាំងអស់នេះ គឺជាកត្តាជំរុញចិត្តក្នុងការពង្រីកការងារបន្ថែមជាបន្តបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឈានទៅក្នុងប្រធានបទស៊ីជម្រៅនៃយុត្តិធម៌អន្តរកាល។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺមិនមែនត្រឹមតែជាអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ក៏ប៉ុន្តែបុគ្គលទាំងនេះគឺជាអ្នករស់រានមានជីវិតពីបួនរបប ដែលហែលឆ្លងកាត់សង្គ្រាម, អស្ថិរភាព និងទុក្ខវេទនាដ៏សោកសង្រេង។ នៅមុនពេលខ្មែរក្រហមឡើងកាន់កាប់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ ប្រទេសកម្ពុជា បានទទួលរងការបំផ្លិចបំផ្លាញសាយភាយពីសង្គ្រាមក្នុងប្រទេសវៀតណាម និងចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងរបស់វៀតណាម។ បន្ថែមលើសពីនេះទៅទៀត បន្ទាប់ពីរងការញាំញីដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលដួលរលំទៅនៅក្នុងឆ្នាំ១៩៧៩ ប្រទេសកម្ពុជា បានបន្តទទួលរងអស្ថិរភាព, ទុរភិក្ស និងជម្លោះផ្ទៃក្នុងអស់រយៈកាលជាងពីរទសវត្សរ៍បន្តទៀត។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលរងការឈឺចាប់ ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយការឈឺចាប់ទាំងនេះ នៅមិនទាន់ត្រូវបានសិក្សាស្រាវជ្រាវបានគ្រប់គ្រាន់ឬពុំមានធនធានគាំពារគ្រប់គ្រាន់នៅឡើយ។ មជ្ឈមណ្ឌលឯកសារកម្ពុជា មានការដឹងគុណចំពោះហិរញ្ញប្បទានដ៏សប្បុរសពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ផ្តល់ឲ្យនៅក្នុងឆ្នាំ២០២១ ដែលអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាអាចពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន នៅលើប្រធានបទនេះ ជាពិសេសកិច្ចការងារដែលផ្តោតទៅលើការបង្កើនការយល់ដឹងអំពីស្ថានភាពសុខភាព និងសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

អ្នករស់រានមានជីវិតពីជម្លោះនានា គឺជាភាគីចូលរួមដ៏ចាំបាច់ ព្រមទាំងជាអ្នកនាំពាក្យដ៏សំខាន់បំផុត ក្នុងការកសាងវប្បធម៌មួយ ដែលគោរពឲ្យតម្លៃចំពោះសិទ្ធិក្នុងការរស់រានមានជីវិត។ អ្នករស់រានមានជីវិតពីជម្លោះទាំងនោះ អាចផ្តល់ជាឱកាសដល់មនុស្សជំនាន់ក្រោយ ក្នុងការសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រ ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន។

អ្នករស់រានមានជីវិតទាំងនេះ ថែមទាំងអាចពន្យល់បកស្រាយថាតើ ប្រវត្តិសាស្ត្រមានទំនាក់ទំនង និងមានសារសំខាន់យ៉ាងដូចម្តេចចំពោះសង្គមបច្ចុប្បន្ន។ អ្នករស់រានមានជីវិត មិនមែនមានតួនាទីត្រឹមតែជាអ្នកថែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែគឺជាសាក្សីរស់ សបញ្ជាក់អំពីការប្តេជ្ញាចំពោះសិទ្ធិក្នុងការរស់រានមានជីវិតថែមទៀតផង។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនអាចនឹងទទួលអនិច្ចកម្មទៅ នារយៈពេលប្រាំទៅដប់ឆ្នាំខាងមុខ ពីព្រោះថាអ្នកទាំងនេះមានវ័យយ៉ាងតិច៧០ឆ្នាំ ឬច្រើនជាងនេះ។ ហេតុនេះ ស្របពេលដែលយើងប្រារព្ធខួបអនុស្សាវរីយ៍នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលជាចំណុចចាប់ផ្តើមនៃដំណើរឆ្ពោះទៅសន្តិភាពនៅក្នុងប្រទេសកម្ពុជា យើងគួរតែឆ្លុះបញ្ចាំងវិះគិតអំពីសិទ្ធិជាសកលក្នុងការរស់រានមានជីវិត និងអ្វីដែលយើងអាចធ្វើបានសម្រាប់ប្រជាជនស្លូតត្រង់ ដែលកំពុងស្ថិតនៅក្នុងតំបន់ជម្លោះនាពេលសព្វថ្ងៃ ក៏ដូចជាសម្រាប់អ្នករស់រានមានជីវិតពីជម្លោះនាអតីតកាល។ សិទ្ធិក្នុងការរស់រានមានជីវិត មិនមែនមានអត្ថន័យថាជាសិទ្ធិដើម្បីអាចនៅរស់រានមានជីវិតប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺជាសិទ្ធិក្នុងការរស់រានមានជីវិតប្រកបដោយកិត្តិយស។ នៅក្នុងប្រទេសកម្ពុជា និងប្រទេសក្រោយជម្លោះដទៃទៀត យើងបានរំលេចអំពីការប្តេជ្ញាចំពោះសិទ្ធិក្នុងការរស់រានមានជីវិត ដោយផ្តើមចេញពីជំហានតូចៗ ក្នុងការធានាថាអ្នករស់រានមានជីវិតពីជម្លោះទទួលបានការគាំពារ, ការយកចិត្តទុកដាក់ និងការគោរពឲ្យតម្លៃ។ នេះគឺជាអ្វីដែលយើងអាចធ្វើបានសម្រាប់ វីរបុរស វីរនារី ដែលរស់រានមានជីវិតពីសម័យអន្ធការ។



**លោក ឆាំង យុ**

គឺជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានបង្កើតជាព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ មានគោលបំណងថ្វាយព្រះរាជកិត្តិយសជាទីសក្ការៈដ៏ខ្ពស់ខ្ពស់បំផុតជូនសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដោយព្រះអង្គមានព្រះរាជតួនាទីដ៏សំខាន់ តែមិនតម្កើងព្រះកាយ ក្នុងការសម្រេចបានស្ថិរភាពនិងភាពរីកចម្រើនសាជាថ្មីម្តងទៀតរបស់កម្ពុជា។ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ បង្កើតឡើងដោយមានការជំរុញចិត្តពីព្រះរាជកាយវិការដឹកនាំដ៏ថ្លៃថ្នូរ និងប្រពៃនៃសម្តេចព្រះវររាជមាតាជាតិខ្មែរ ចំពោះប្រជាជាតិកម្ពុជា ហើយព្រះរាជកាយវិការនេះ នៅតែជាកត្តាជំរុញចិត្តសម្រាប់មនុស្សជំនាន់ក្រោយថែមទៀតផង។ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ មានតម្កល់ទុកឯកសារនិងវត្ថុស្តីអំពីប្រវត្តិសាស្ត្រកម្ពុជា ដោយរួមបញ្ចូលនូវឯកសារមួយផ្នែកដែលរំលេចអំពីព្រះរាជសកម្មភាពរបស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ យាងចូលរួមនៅក្នុងកិច្ចចរចាឈានទៅសម្រេចបានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។

# វ៉ែន វន ហៅ វង់ ម៉ន អនុលេខាវរសេនាតូច១៩ វរសេនាធំ៧០ កងពលទី២ ភូមិភាគពាយ័ព្យ

*មីន សាណាស់*



កងទ័ពបដិវត្តន៍ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ វ៉ែន វន ឈ្មោះក្នុងបដិវត្តន៍ វង់ ម៉ន ភេទប្រុស អាយុ២៥ឆ្នាំ (ក្នុងឆ្នាំ១៩៧៨)។ ខ្ញុំមានស្រុកកំណើតកើតនៅភូមិព្រៃធំ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ កាលពីខ្ញុំអាយុ៧ឆ្នាំ ឪពុកម្តាយខ្ញុំយកខ្ញុំទៅរៀននៅសាលាបឋមសិក្សាវត្តលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំរៀនបានដល់ថ្នាក់ទី៧ ក៏ឈប់រៀន។ នៅឆ្នាំ១៩៧០ ខ្ញុំ និងឪពុកម្តាយរបស់ខ្ញុំចេញទៅធ្វើស្រែនៅភូមិដំណាក់ត្រប់ ឃុំដំណាក់ត្រប់ ស្រុកបាកាន ខេត្តពោធិ៍សាត់។ មកដល់ខែសីហា ឆ្នាំ១៩៧០ ខ្ញុំបានចូលក្នុងអង្គភាពពេទ្យភូមិដំណាក់ត្រប់ ឃុំដំណាក់ត្រប់ ស្រុកបាកាន តំបន់២។ មកដល់ចុងឆ្នាំ១៩៧០ អង្គការបានឲ្យខ្ញុំចូលកងទ័ពតំបន់២ រយៈពេលមួយខែ។ ចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ អង្គការចាត់តាំងខ្ញុំឲ្យមកធ្វើការខាងផ្នែកសន្តិសុខវិញ។

ក្រោយមក នៅឆ្នាំ១៩៧៣ អង្គការផ្លាស់ខ្ញុំមកនៅខាងគមនាគមន៍តំបន់២ ក្រោមការដឹកនាំរបស់ឈ្មោះ ញា ដែលមានតួនាទីជាប្រធានក្រសួង

គមនាគមន៍តំបន់៧ ប៉ុន្តែបច្ចុប្បន្ន ញ៉ា គឺជាប្រជាជន នៅភូមិប្រហាល ឃុំដំណាក់ត្រប់ ស្រុកបាកាន តំបន់២។ នៅខែកញ្ញា ឆ្នាំ១៩៧៣ ញ៉ា បានអប់រំខ្ញុំនិងសមាជិកចំនួនបួននាក់ទៀត រួមមាន ១) ឈ្មោះ សៀង មានតួនាទីជាយុទ្ធជន និង បើក ឡានពាណិជ្ជកម្មនៅក្រុងបាត់ដំបង ២) ឈ្មោះ ហុន មានតួនាទីជាយុទ្ធជន ៣) ឈ្មោះ ឡាយ តួនាទីក្លាប់មិនបាន ប៉ុន្តែពេលជួបប្រាប់ខ្ញុំថានៅយោធាភាគប្រចាំមុខសញ្ញាផ្ទល់បត់ និង ៤) ឈ្មោះ សាវុធ អតីតប្រជាជន និងធ្លាប់ធ្វើការនៅរោងក្រឡឹងដែក និងជួលជុល ឡានមង្គលបូរី។ ខ្លឹមសារដែល ញ៉ា អប់រំគឺ មិនឲ្យរណបប្រទេសចិន ដូរមកគាំទ្រប្រទេសអាមេរិក។ ក្រោយពីខ្ញុំបានទទួលការអប់រំរួច ញ៉ា បាននាំពួកខ្ញុំទៅជួបឈ្មោះ វ៉ាញ អតីតសាស្ត្រាចារ្យពេទ្យនារី និងជាលេខាតំបន់២ នៅភូមិតាគោក ដើម្បីឲ្យបញ្ចូលឈ្មោះពួកខ្ញុំក្នុងខ្សែ សេ.អ៊ី.អា ព្រមទាំងឲ្យពួកខ្ញុំគោរពទង់ជាតិ សេ.អ៊ី.អា, ផឹកទឹកសម្បថ និងសុំឲ្យខិតខំបំពេញភារកិច្ចឲ្យបានល្អ ហើយស្មោះត្រង់ជាដាច់ខាត។

ក្រោយចូលសមាជិក សេ.អ៊ី.អា រួច ញ៉ា បានឲ្យក្រុមខ្ញុំទៅទាក់ទងជាមួយឈ្មោះ ជុំ មានតួនាទីជាអនុប្រធានគមនាគមន៍តំបន់២ ដើម្បីសួរនាំអំពីសភាពការណ៍ដែល ជុំ បានកសាងកម្លាំង និងរាយការណ៍មកកាន់ក្រុមខ្ញុំដើម្បីងាយស្រួលធ្វើការជាមួយក្រុម ជុំ។ ចំណែកខ្ញុំផ្ទាល់គឺត្រូវស្នាក់នៅជាមួយ ជុំ ដើម្បីចាំទទួលសំបុត្រពី ជុំ យកទៅឲ្យ ញ៉ា ផ្ទាល់។ ពេលបានទទួលសំបុត្រពី ជុំ ខ្ញុំយកទៅជូន ញ៉ា រួចខ្ញុំក៏សុំច្បាប់ ញ៉ា មកលេងផ្ទះ ហើយក៏បានប៉ះពាល់សីលធម៌ជាមួយនារី សម្បត្តិ។ ពេលនោះរដ្ឋអំណាចបានដឹងរឿងខ្ញុំ ហើយក៏ចាប់ខ្ញុំយកទៅឃុំឃាំងនៅសាលាឃុំអស់រយៈពេល២ថ្ងៃ រួចហើយបញ្ជូនខ្ញុំមកឃុំឃាំងនៅសាលាស្រុកមួយថ្ងៃទៀត។ បន្ទាប់មកសាលាស្រុក ក៏បញ្ជូនខ្ញុំបន្តមកអប់រំនៅមន្ទីរតំបន់២ ហើយបានកាត់ក្តីឲ្យខ្ញុំជាប់មន្ទីរឃុំឃាំងរយៈពេល៦ខែ ដែលជាហេតុនាំឲ្យខ្ញុំដាច់ខ្សែទាក់ទងជាមួយ ញ៉ា និងសមាជិកខ្ញុំទាំងបួននាក់។

នៅខែមីនា ឆ្នាំ១៩៧៤ អង្គការបានដោះលែងខ្ញុំចេញពីមន្ទីរឃុំឃាំង ឲ្យវិលត្រឡប់មកផ្ទះវិញ។ ពេលទទួលបានសេរីភាព ខ្ញុំក៏ចូលក្នុងកងទ័ពវរសេនាតូច១២។ ខ្ញុំមករស់នៅក្នុងកងទ័ពបានមួយរយៈ ក៏ឈ្មោះ រឿយ មានតួនាទីជាបញ្ជាការវរសេនាតូច១២ (បច្ចុប្បន្នស្លាប់នៅសមរភូមិគាស់ក្រឡ) បានអប់រំឲ្យខ្ញុំប្រឆាំងបដិវត្តន៍ បើមិនដូច្នេះទេគឺអង្គការបដិវត្តន៍នឹងឲ្យប្រជាជនហូបអង្ករកំប៉ុងជាមិនខាន។ ក្រោយមក រឿយ ក៏ណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ សុំ មានតួនាទីជាមេបញ្ជាការនៅសេនាធិកា (បច្ចុប្បន្នស្លាប់នៅសមរភូមិគាស់ក្រឡ)។

នៅខែមេសា ឆ្នាំ១៩៧៤ រឿយ បានប្រាប់ខ្ញុំឲ្យដឹកនាំធ្វើសកម្មភាពដូចតទៅ៖ ធ្វើយ៉ាងណាឲ្យកងទ័ពចាញ់នៅសមរភូមិ ហើយនាំគ្នារត់ទៅផ្ទះវិញ និងកសាងកម្លាំងបន្ថែម ជាពិសេសកម្លាំងកម្មាភិបាល។ ពេលនោះខ្ញុំបានកសាងឈ្មោះ យន មានតួនាទីជាប្រធានកងតូច វរសេនាតូច១២ និងជាសមាជិកកងធំកាំភ្លើងធំប្រចាំបន្ទាយ (គ) ឲ្យធ្វើសកម្មភាពជាមួយគ្នា, ឈ្មោះ ផុន មានតួនាទីជាសមាជិកកងតូច កងធំ១៧ វរសេនាតូច១២ រស់នៅសហគមន៍កងទ័ពវត្តបុស្សី ស្រុកមោង តំបន់១, ឈ្មោះ វ៉ែន មានតួនាទីជាប្រធានកងតូច អនុសេនាធំ១៧ វរសេនាតូច១២ បច្ចុប្បន្នអង្គការដកមកកន្លែងបាតុភាពកកោះ មុនដកមាននាទីជាប្រធានវរសេនាតូចរថក្រោះរបស់ភូមិភាគ។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ ខ្ញុំបានធ្វើចលនាឲ្យកងទ័ពក្នុងសមរភូមិគាស់ក្រឡរត់បោលជួរអស់ជាង១០នាក់ ហើយខណៈនោះខ្ញុំក៏ត្រូវរបួស។ ពេលនោះ អង្គការ បានបញ្ជូនខ្ញុំមកសម្រាកព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេល៨ខែ ទើបខ្ញុំបានជាសះស្បើយ។

នៅខែមីនា ឆ្នាំ១៩៧៥ ខ្ញុំចេញពីមន្ទីរពេទ្យមករស់នៅក្នុងអង្គភាពវរសេនាតូច១២ដដែល រួចភ្ជាប់ទំនាក់ទំនងជាមួយឈ្មោះ យន និង វ៉ែន។ ខ្ញុំបានសួរទៅអ្នកទាំងពីរអំពីដំណើរការនៃផែនការតើបានដំណើរការដល់ណាហើយ? ពេលនោះ អ្នកទាំងពីរបានប្រាប់ខ្ញុំថាឈ្មោះ សំ និង រឿយ បានស្លាប់ក្នុងសមរភូមិគាស់ក្រឡហើយ។ ចំណែកឈ្មោះ ផុន ចាប់តាំងពីអង្គការដកទៅខាងសេដ្ឋកិច្ច គឺដាច់

ការទាក់ទងរហូតមិនដែលបានជួបទេមកដល់ពេលនេះ។ យន និង វ៉ែន បានបើកប្រជុំលើកផែនការ និងណែនាំសមាជិកចំនួន៥នាក់បន្ថែមទៀតឲ្យខ្ញុំស្គាល់ ដូចជា ឈ្មោះ ហាំ មានតួនាទីជាប្រធានក្រសួងភស្តុភារភូមិភាគ, សឿន មានតួនាទីជាប្រធានវរសេនាធំកាំភ្លើងធំ, តេន មានតួនាទីជាបញ្ជាការវរសេនាធំ៧០ កងពលទី២, វ៉ែត មានតួនាទីជាសមាជិកវរសេនាធំ៧០ កងពលទី២ និង ឡឹង មានតួនាទីជាប្រធានក្តាប់កម្មកររថភ្លើងបាត់ដំបង។ ខ្លឹមសារប្រជុំគឺត្រូវត្រៀមរៀបចំវាយ ក្រោយពេលសង្គ្រាមរវាងកងទ័ពរំដោះ និងទាហាន លន់ នល់ ចប់ភ្លាមៗ, ត្រូវបើកឲ្យកងទ័ពរំដោះទៅលេងផ្ទះ ទុកតែកម្លាំងមួយចំនួន ដើម្បីកាត់បន្ថយកម្លាំងបដិវត្តន៍ និងចំណុចចុងក្រោយគឺត្រូវកសាងកម្លាំងបន្តទៀត ជាពិសេសត្រូវអូសទាញកម្មាភិបាល។

ក្រោយប្រទេសបានរំដោះ ផែនការទាំងប៉ុន្មានមិនបានសម្រេចទេ ព្រោះអង្គការបានជម្លៀសប្រជាជនចេញពីទីក្រុងអស់ ចំណែកឯកងទ័ពរំដោះក៏ត្រូវបែកគ្នាអស់ ជាហេតុនាំឲ្យបាត់ការទាក់ទងកងកម្លាំងទាំងអស់។ ខ្ញុំផ្ទាល់អង្គការបានបញ្ជូនឲ្យទៅធ្វើស្រែនៅភូមិកកោះ។ មកដល់ខែមិថុនា ឆ្នាំ១៩៧៥ សឿនបានប្រមូលកម្មាភិបាលដែលនៅសេសសល់ទាំងអស់មករៀបចំជាកងរថក្រោះ។ សឿនក៏ណែនាំខ្ញុំ, យន និង វ៉ែនឲ្យស្គាល់ឈ្មោះ ខុម មានតួនាទីជាបញ្ជាការកងរថក្រោះ និង ឈ្មោះ រុន មានតួនាទីជាប្រធានកងធំទី១ វរសេនាតូច១៩ វរសេនាធំ៧០ កងពលទី២។ ក្រោយមកទៀតក្រុមរបស់ខ្ញុំទៅបន្តកសាងកម្លាំងបានបន្តបន្ទាប់ ដូចជា៖ ១) ឈឿប ២) សុន ៣) សឿន និង ៤) សារឹម មានតួនាទីជាប្រធានវរសេនាធំ៧០ កងពលទី២។

នៅឆ្នាំ១៩៧៦ ឈ្មោះ សារឹម បានចាត់តាំងខ្ញុំជាប្រធានកងធំវរសេនាតូច១៩ វរសេនាធំ៧០ កងពលទី២។ នៅខែមីនា ឆ្នាំ១៩៧៧ ខ្ញុំបានជួប វាញ, ហាំ, វ៉ែន, និង អាន ហើយអ្នកទាំងនោះបាននាំខ្ញុំទៅជួប អ៊ិន តាំ នៅអូរឡាក់។ ប៉ុន្តែកាលនោះខ្ញុំនិងអានមិនបានចូលទៅជួបប្រជុំជាមួយគេទេ គ្រាន់តែនៅយាមលើមាត់អូរកុំឲ្យអ្នកដទៃចូលមក។ ក្រោយប្រជុំរួច ខ្ញុំក៏វិលត្រឡប់មកខេត្តប៉ៃលិនវិញ ប៉ុន្តែ វ៉ែន បានហៅខ្ញុំ និង អាន មកប្រាប់ឲ្យដឹងពីសកម្មភាពប្រជុំមុននេះថា «យើងជួបពួក អ៊ិន តាំ អម្បាញ់មិញគឺទាក់ទងឲ្យគេចូលមកធ្វើសកម្មភាពតាមផ្លូវលេខ១០ ដូច្នេះយើងត្រូវបើកផ្លូវឲ្យគេចូលមកកាន់អូរបេក្រ និង ឡាក់៦៨ ពីរកន្លែងនេះគឺយើងបើកឲ្យគេចូលមក។ ហេតុដូច្នេះចាប់ពីថ្ងៃនេះទៅយើងមិនបាច់ការពារទេ ហើយយើងនាំគ្នាទៅធ្វើចម្ការអំពៅជាមួយមិត្ត ហាំ ចំណែកអាវុធយើងទុកក្នុងកងវរសេនាតូចតែ៥០ដើមបានហើយ។

នៅឆ្នាំ១៩៧៧ ខ្ញុំបានស្គាល់ឈ្មោះ កង់ មានតួនាទីជាប្រធានកងវរសេនាតូច១៩ វរសេនាធំ៧០ កងពលទី២ តាមរយៈ វ៉ែន។ កង់ បាននាំខ្ញុំទៅប្រជុំនៅស្ពោ ដែលមានគ្នាទាំងអស់១១ នាក់ រួមមាន៖ ១) ខ្ញុំ ២) កង់ ៣) ឆន ៤) បិច ៥) យ៉ន ៦) រិត ៧) ចុង ៨) តឿម ៩) ហុង ១០) លី និង ១១) ម៉ៅ។ ខ្លឹមសារនៃការប្រជុំគឺ៖ កងកម្លាំងយើងត្រូវអង្គការចាប់អស់ហើយ ហេតុនេះ គាត់ (កង់) ត្រូវទាក់ទងទៅ អ៊ិន តាំ ដើម្បីត្រៀមវាយនៅខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ១៩៧៧ នេះឲ្យហើយ។

នៅខែមករា ឆ្នាំ១៩៧៨ អ៊ិន តាំ បានតបមកវិញថា ផែនការត្រូវបែកការអស់ហើយ អង្គការក៏កម្ទេចបក្សពួកយើងអស់ដែរ ហើយកងកម្លាំងតាមព្រំដែនសៀមគឺត្រូវដកចេញទាំងអស់។ ហេតុដូច្នេះ កងកម្លាំងយើងត្រូវធ្វើយ៉ាងណាទាក់ទងកម្ទេចកម្មាភិបាលខ្មែរក្រហម ប៉ុន្តែបើបែកការណ៍គឺត្រូវនាំគ្នារត់ចូលទៅទាក់ទងជាមួយទាហានសៀម។ ពេលនោះ ខ្ញុំបានទទួលធ្វើសកម្មភាពនេះឲ្យទាល់តែបាន ប៉ុន្តែមិនទាន់អនុវត្តផង ក៏ត្រូវអង្គការចាប់ខ្លួនបាននៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៨។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00614។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ វ៉ែន វន ហៅ វង់ ម៉ន ពិតប្ យ៉ាងណានោះទេ?***

# ក្រសួងមហាផ្ទៃផ្តល់ការអនុញ្ញាត និងកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា

## ក្នុងការផ្សព្វផ្សាយកូនសៀវភៅអំពីសុខភាព និងផ្ទាំងរូបភាពសុខភាពជូនប្រជាពលរដ្ឋ

**សោម ប៊ុនថន**




សៀវភៅព័ត៌មានអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តបតាមសំណើរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា សុំក្រសួងមហាផ្ទៃជួយអន្តរាគមន៍ទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីផ្តល់កិច្ចសហការក្នុងការទទួលកូនសៀវភៅព័ត៌មានអំពីសុខភាព ផ្ទាំងរូបភាពសុខភាព និងផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម អ៊ុំ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជំនួសឯកឧត្តម ស សុខា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានផ្តល់ការអនុញ្ញាត និងកិច្ចសហការក្នុងការទទួលកូនសៀវភៅព័ត៌មានអំពីសុខភាព និងផ្ទាំងរូបភាពសុខភាព និងជួយផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋនៅតាមបណ្តាក្រុង ស្រុក ខណ្ឌ នៃរដ្ឋបាលរាជធានី ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការផ្តោតលើការប្រមូល ការចងក្រងឯកសារ ការបោះពុម្ពសៀវភៅ និងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សានុសិស្ស ក្នុងគោលបំណងយុត្តិធម៌ និងការចងចាំ។ ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការទាក់ទងនឹងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ គម្រោងនេះធ្វើយ៉ាងណាឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបាននូវសេវាសុខភាពកាន់តែប្រសើរឡើង និងមានការចូលរួមពីក្រុមនិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលត្រូវជាកូនចៅ

របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ។ ក្រុមនិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមាណជាង១០៣០នាក់ បានត្រឡប់ទៅធ្វើការងារនៅសហគមន៍របស់ខ្លួន និងបានចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣២០០០នាក់ ដែលកំពុងរស់នៅតាមតំបន់ជនបទដាច់ស្រយាលក្នុងប្រទេសកម្ពុជា។

កូនសៀវភៅអំពីសុខភាព និងផ្ទាំងរូបភាពសុខភាពនេះ បានបង្ហាញអំពីព័ត៌មានសុខភាពទូទៅដែលកើតមានចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅទូទាំងប្រទេសកម្ពុជា ដែលផ្អែកលើលទ្ធផលនៃការស្ទង់មតិចំនួន ៣២០០០នាក់ នៅចុងឆ្នាំ២០២២ ដោយក្រុមនិស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើគម្រោង «ការលើកកម្ពស់លើសិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ សៀវភៅនេះផ្តោតលើចំណុចសំខាន់ពីរយ៉ាងគឺ៖

១) សារសំខាន់នៃការពិនិត្យសុខភាព សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

២) ណែនាំឲ្យអ្នករស់រានមានជីវិតពីររបបខ្មែរក្រហមឲ្យយល់ដឹងអំពីរបៀបរស់នៅឲ្យមានសុខភាពល្អ ការយល់ដឹងពីមូលហេតុដែលធ្វើឲ្យមានជំងឺលើមនុស្សចាស់ និងការយល់ដឹងអំពីរបៀបបង្ការកុំឲ្យមានជំងឺទាំង១០ ដែលភាគច្រើនកើតឡើងចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

បន្ថែមលើនេះ ការពិនិត្យសុខភាពពិតជាមានសារសំខាន់ខ្លាំងណាស់ និងមិនគួរមើលរំលងឡើយ សម្រាប់ការថែទាំសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរកក្រហម ព្រោះអ្នករស់រានមានជីវិតពីរបបខ្មែរកក្រហម ភាគច្រើនដែលមានអាយុ៦០ឆ្នាំ និងលើសពី៦០ឆ្នាំ (ក្នុងចំណោមមនុស្ស៣២០០០នាក់) ងាយនឹងមានជំងឺឈឺថ្កាត់ផ្សេងៗ។ ម្យ៉ាងទៀត ការពិនិត្យនិងរកឃើញថាមានជំងឺ គឺជាជំនួយដើម្បីអាចមានលទ្ធភាពព្យាបាលជំងឺឲ្យបានជោគជ័យ និងទាន់ពេលវេលា។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សំបុត្ររបស់ក្រសួងមហាផ្ទៃផ្តល់ការអនុញ្ញាត និងកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការផ្សព្វផ្សាយកូនសៀវភៅអំពីសុខភាព និងផ្ទាំងរូបភាពសុខភាពជូនប្រជាពលរដ្ឋ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា បានស្រាវជ្រាវរកឃើញថា «មានប្រជាជនចំនួន៥លាននាក់ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលស្មើនឹង៣៣% នៃប្រជាជនទូទាំងប្រទេសកម្ពុជា។ អ្នករស់រានមានជីវិតទាំងនេះបានកសាងប្រទេសឡើងវិញពីបាតដៃទទេ ដែលត្រូវជាមាមីងអ៊ំយាយ និងតារបស់យើង។ បច្ចុប្បន្ន អ្នកទាំងនេះមានវ័យកាន់តែចាស់ និងចាប់ផ្តើមមានជំងឺ។ នៅក្នុងចំណោម៣៣% នៃអ្នករស់រានជីវិតពីរបបខ្មែរក្រហមទាំងនេះកំពុងប្រឈមនឹងជំងឺ១០យ៉ាង ដូចគ្នា រួមមាន១) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្ត ៥) ជំងឺបេះដូង ៦) ជំងឺឈឺសន្លាក់ ៧) ជំងឺហឺតរ៉ាំរ៉ៃ ៨) ជំងឺទឹកនោមផ្អែម ៩) ជំងឺរបេង និង១០) ជំងឺផ្តួតជ្រូក។

# ចំណុះទូករាមាជើងព្រៃ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ទទួលបានសៀវភៅ

## « សាក្សីប្រវត្តិសាស្ត្រ » កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»

**លី ជេទីក**



កីឡាករប្រណាំងទូករាមាជើងព្រៃ ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ កីឡាករប្រណាំងទូកចំនួន២៥នាក់ ចំណុះទូករាមាជើងព្រៃ មកពីស្រុកជើងព្រៃ ខេត្តកំពង់ចាម ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ, អាវយឺត និងមួក ពីមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ កីឡាករចំណុះទូករាមាជើងព្រៃ គឺស្ថិតនៅវត្តពោធិ៍ព្រះទន្លា ភូមិបឹងជ្រោយ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។






ទូករាមាជើងព្រៃ ស្ថិតនៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឱកាសនោះ លោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម លើកឡើងអំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រដ៏មានតម្លៃសម្រាប់ការសិក្សាឈ្វេងយល់ ចេញពីព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមសម្តេចព្រះ នរោត្តម សីហនុ យាងមកកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ក្នុងឆ្នាំ១៩៧៣។

ជាមួយគ្នានេះដែរ លោក លី ដេវីត លើកទឹកចិត្តដល់កីឡាករប្រណាំងទូកចំណុះទូករាមាជើងព្រៃទាំងអស់ ដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ព្យាយាមអានឲ្យចប់ដើម្បីបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ និងរក្សាទុកជាឯកសារប្រវត្តិសាស្ត្រផ្ទាល់ខ្លួន និងជូនពរឲ្យកីឡាករចំណុះទូករាមាជើងព្រៃទទួលជ័យជម្នះក្នុងការប្រកួតនេះ។

លោក រឿន សាវ៉ាង អាយុ៦៥ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាប្រធានភូមិបឹងជ្រោយ និងជាប្រធានក្រុមការងារដឹកនាំទូករាមាជើងព្រៃ ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានផ្តល់សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរដែលជាសៀវភៅឯកសារប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់ ដល់កីឡាករចំណុះទូករាមាជើងព្រៃដែលត្រូវជាកូនចៅរបស់ទ្រង់ និងសម្ភារមួយចំនួនរួមមាន អាវយឺត និងមួក។

លោក **រឿន សាវ៉ាង** រៀបរាប់ពីរឿងរ៉ាវរបស់គាត់ដែលបានឆ្លងកាត់របបខ្មែរក្រហមថា គាត់នៅក្នុងកងចល័តបុរសក្នុងរបបខ្មែរក្រហម និងត្រូវធ្វើស្រែនៅតាមការដ្ឋានផ្សេងៗក្នុងស្រុកជើងព្រៃ និងតំបន់ផ្សេងទៀត។ លោក រឿន សាវ៉ាង បានលើកឡើងអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រជាពិសេស ប្រវត្តិសាស្ត្រផ្ទាល់ខ្លួន។

ជាចុងក្រោយ លោក រឿន សាវ៉ាង និងកីឡាករចំណុះទូករាមាជើងព្រៃទាំងអស់ សូមថ្វាយព្រះពរដល់ហ្លួងម៉ែ ឲ្យមានព្រះជន្មាយុយឺនយូរ និងព្រះរាជសុខភាពល្អបរិបូរណ៍ដើម្បីជាម្លប់ដល់ប្រជានុរាស្ត្រកម្ពុជា និងជូនពរដល់លោកនាយក ព្រមទាំងបុគ្គលិកព្រះរាជបណ្ណាល័យហ្លួងម៉ែ និងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៃមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ ឲ្យមានសុខភាពល្អ និងសម្រេចការងារគ្រប់ភារកិច្ច។

# មេឃុំព្រៃផ្ដៅ ចាន់ អិន រំឭកអំពីអនុស្សាវរីយ៍ធ្វើកងទ័ពខ្មែរក្រហម ក្រោយពេលទទួលសៀវភៅ

## «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ផេង ពង្សរ៉ាស៊ី



លោក ចាន់ អិន មេឃុំព្រៃផ្ដៅ បានរំឭកពីប្រវត្តិធ្លាប់ធ្វើជាកងទ័ពខ្មែរក្រហមប្រាប់ដល់ប្រជាជនក្នុងភូមិ ក្រោយពេលដែលគាត់បានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ទៅកាន់អ្នកភូមិក្នុងឃុំព្រៃផ្ដៅ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ លោក ចាន់ អិន មេឃុំព្រៃផ្ដៅ បានរំឭកអំពីប្រវត្តិធ្លាប់ធ្វើជាកងទ័ពខ្មែរក្រហម ក្រោយពេលដែលគាត់បានទទួល និងបានអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែររួចមក។ ការលើកឡើងរបស់លោក ចាន់ អិន គឺដើម្បីធ្វើជាគំរូដល់អ្នកភូមិឯទៀត ឲ្យចូលរួមក្នុងការចែករំលែកបទពិសោធន៍

របស់ខ្លួនឆ្លងកាត់របបខ្មែរក្រហម ប្រាប់ដល់ក្មេងៗជំនាន់ក្រោយ និងដើម្បីចងក្រងទុកជាឯកសារប្រវត្តិសាស្ត្រនាពេលអនាគត។ លោកបានលើកដៃឆ្វេង រួចបង្ហាញពីស្នាមរបួសត្រង់កដៃ ថាជាស្នាមរបួសដែលបន្សល់ទុកតាំងពីរបបខ្មែរក្រហមមក។ ស្នាមរបួស (បាក់កដៃ) នេះ គឺជាស្នាមរបួសដោយគ្រាប់កាំភ្លើងក្នុងពេលប្រយុទ្ធនឹងសត្រូវកាលពីទសវត្សរ៍ឆ្នាំ១៩៧០។ លោកបានចូលធ្វើកងទ័ពខ្មែរក្រហម តាំងពីលោកមានអាយុ១៥ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧២ ដោយសារតែឮការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ និងម៉្យាងទៀតដើម្បីចង់ការពារគ្រួសារពីការគំរាមកំហែងពីពួកកម្មាភិបាលមូលដ្ឋាន ដែលតែងតែចាប់កំហុសគ្រួសាររបស់គាត់។ ឪពុកម្តាយរបស់លោក ចាន់ អ៊ិន គឺជាអ្នកមានទ្រព្យសម្បត្តិនៅក្នុងភូមិ។ ក្រោយឆ្នាំ១៩៧៩ ចាន់ អ៊ិន បានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ហើយបច្ចុប្បន្ន គាត់បម្រើការងារជាប្រធានក្រុមប្រឹក្សាឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស។

ខាងក្រោមនេះ ជាការដកស្រង់សម្តីរបស់លោក ចាន់ អ៊ិន ចេញពីប្រវត្តិរបស់គាត់ដែលឆ្លងកាត់របបខ្មែរក្រហម នៅក្នុងកម្មវិធីចែកចាយសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ៖

ខ្ញុំបានអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» បានខ្លះៗដែរ ហើយព្រឹត្តិការណ៍នៅក្នុងសៀវភៅនេះបានកើតឡើងក្នុងឆ្នាំ១៩៧៣ ពេលដែលសម្តេចព្រះ នរោត្តម សីហនុ យាងមកកាន់ប្រទេសកម្ពុជាមុនពេលដែលខ្ញុំត្រូវបានបញ្ជូនទៅកាន់ភាគឦសានប្រទេសនៅចុងឆ្នាំ១៩៧៣។ ដំបូងឡើយ ខ្ញុំមិនបានដឹងរឿងនេះទេ ប៉ុន្តែនៅឆ្នាំ១៩៧៤ ក្រុមខ្មែរក្រហមបានចែកទស្សនាវដ្តី (ភ្លេចឈ្មោះ) ឲ្យកងទ័ពមើល។ កាលនោះ ខ្ញុំគឺជាកងទ័ពខ្មែរក្រហមឈរជើងនៅភាគឦសាន។ ខ្ញុំបានរៀនដល់ត្រឹមថ្នាក់ទី៧ ពីសង្គមចាស់។ ដូច្នេះ ខ្ញុំអាចអានអក្សរបាន។ នៅពេលនោះទើបខ្ញុំដឹងថា សម្តេចឪបានមកដល់ស្រុកខ្មែរ ហើយជួបជាមួយមេធំៗខ្មែរក្រហម។ ខ្ញុំមានកម្លាំងចិត្តតស៊ូណាស់ នៅពេលដែលបានអាន និងឃើញរូបថតសម្តេចថតជាមួយក្រុមមេធំៗខ្មែរក្រហម។

ខ្ញុំសូមនិយាយអំពីប្រវត្តិរបស់ខ្ញុំកាលពីខ្ញុំចេញទៅធ្វើកងទ័ពខ្មែរក្រហម។ ខ្ញុំបានចេញពីផ្ទះទៅធ្វើទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧២ តាំងពីខ្ញុំមានអាយុ១៥ឆ្នាំ។ មូលហេតុដែលនាំឲ្យខ្ញុំចេញពីផ្ទះចូលបម្រើជាទ័ពខ្មែរក្រហមនេះ គឺដោយសារតែចង់ឲ្យប្រទេសជាតិមានសម្តេចព្រះ នរោត្តម សីហនុ ជាមេដឹកនាំដូចពីមុន។ ខ្ញុំបានស្តាប់ឮការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ។ ខ្ញុំចង់ចូលរួមណាស់។ តាំងពី លន់ នល់ ធ្វើរដ្ឋប្រហារមក ឪពុកម្តាយរបស់ខ្ញុំដែលជាអ្នកមាននៅក្នុងភូមិ ត្រូវប្រធានឃុំ ប្រធានភូមិ និង កម្មាភិបាលខ្លះទៀត គំរាមកំហែងរឹតត្បិត និងចាំតែចាប់កំហុសគ្រប់បែបយ៉ាង។ ថ្ងៃមួយ នៅពេលដែលខ្ញុំត្រឡប់មកពីភ្នំពេញវិញ ខ្ញុំបានស្តាប់ឮឪពុកម្តាយ ខ្ញុំត្អូញត្អែរពីភាពលំបាករបស់គាត់ក្នុងការរកស៊ីចិញ្ចឹមជីវិត ដោយសារតែមានការរឹតត្បិត និងមើលងាយពីពួកកម្មាភិបាលបដិវត្តន៍។ ខ្ញុំសូមបញ្ជាក់ដែរថា ខ្ញុំបានទៅបន្តការសិក្សារបស់ខ្ញុំនៅទីក្រុងភ្នំពេញ ហើយស្នាក់នៅជាមួយបងប្អូននៅទីនោះ។ យូរៗទើបខ្ញុំត្រឡប់មកលេងស្រុកកំណើតម្តង។ ដោយសារខ្ញុំជាមនុស្សឆ្លាត ខ្ញុំបានដឹងពីសភាពការជាក់ស្តែងក្នុងពេលនោះថា មេឃុំ មេភូមិ និងកម្មាភិបាលខ្មែររំដោះឯទៀតមើលងាយគ្រួសារខ្ញុំ ដោយសារគ្រួសារខ្ញុំជាអ្នកមាន និងមិនជ្រះស្រឡះជាមួយអង្គការបដិវត្តន៍។ ខ្ញុំបានពិចារណា និងគិតគូរល្អិតល្អន់ថា ដើម្បីប្រទេសជាតិ និងគ្រួសារ ខ្ញុំត្រូវតែស្ម័គ្រចិត្តធ្វើកងទ័ពខាងខ្មែររំដោះ។ បន្ទាប់មក ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហមនៅស្រុកកំណើតតែម្តង។ ចាប់តាំងពីពេលនោះមក គ្រួសាររបស់ខ្ញុំលែងមាននរណាមកបៀតបៀនទៀតហើយ។ បន្ទាប់ពីចូលបម្រើកងទ័ពរួច ខ្ញុំតែងតែឆ្លៀតពេលសុំប្រធានអង្គភាពមកលេងផ្ទះ ហើយខ្ញុំតែងតែសំញ៉ែងកាំភ្លើងអាការរបស់ខ្ញុំដែលអង្គការបើកឲ្យដើម្បីឲ្យមេឃុំ មេភូមិបានឃើញ និង

ញញើត។ ជួនកាល ខ្ញុំបានស្នើសុំទៅកាន់មេឃុំ មេភូមិទាំងនោះ ឲ្យជួយរកមាន់ទា និងសាច់ ដើម្បីយកទៅជួយដល់រោងបាយធ្វើម្ហូបអាហារសម្រាប់កងទ័ពទៀតផង ហើយអ្នកទាំងនោះមិនដែលប្រកែកជាមួយខ្ញុំទេ។ នៅចុងឆ្នាំ១៩៧៣ ខ្ញុំត្រូវបានបញ្ជូនទៅកាន់ខេត្តរតនៈគិរី ដើម្បីប្រយុទ្ធជាមួយសត្រូវ។ នៅដើមឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនមកវិញ ដើម្បីត្រៀមវាយប្រយុទ្ធយកទីក្រុងភ្នំពេញពីពួកលន់ នល់។ ខ្ញុំធ្លាប់បានចូលវាយផ្ដាច់ និងគ្រប់គ្រងព្រលានយន្តហោះពោធិ៍ចិនតុង នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ នៅថ្ងៃទី១៧ មេសា ១៩៧៥ ខ្ញុំបានចូលដល់ទីក្រុងភ្នំពេញជាមួយកងទ័ពខ្មែរក្រហមឯទៀត។ ខ្ញុំបានចូលឆែកឆេរនៅតាមអគារមួយចំនួននៅម្ដុំអង់តែនទូរទស្សន៍ និងកន្លែងផ្សេងទៀត។ នៅថ្ងៃទី១៨ ខែមេសា ខ្ញុំបានដិះកង់ចេញពីកង ដើម្បីស្វែងរកបងប្អូនរបស់ខ្ញុំ ដែលខ្ញុំធ្លាប់រស់នៅជាមួយកាលពីមុនខ្មែរក្រហម។ ខ្ញុំរកពួកគាត់មិនឃើញឡើយ។ ផ្ទះរបស់គាត់ត្រូវបិទទ្វារ និងគ្មានមនុស្សរស់នៅ។ នៅថ្ងៃទី១៩ ខ្ញុំបានវិលត្រឡប់ទៅកាន់កងរបស់ខ្ញុំវិញ ហើយមិត្តឯទៀតសួរនាំខ្ញុំពីការបាត់ខ្លួនខ្ញុំ។ ខ្ញុំបានកុហកអ្នកទាំងនោះថាខ្ញុំវង្វេងផ្លូវ។

ប្រហែលជាក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ខ្ញុំធ្លាប់បានទៅទទួលសម្ដេច សីហនុ នៅព្រលានយន្តហោះពោធិ៍ចិនតុង។ ខ្ញុំឃើញមានវត្តមានរបស់សម្ដេចម៉ែ និងសម្ដេច ប៉ែន នុត ដង្ហែរសម្ដេចព្រះ នរោត្តម សីហនុ មកដែរ។ ក្នុងពេលទទួលនោះ ខ្ញុំក៏សង្កេតឃើញមាន សុន សេន, ហ៊ូ យន់, ហូ នឹម, វន់ វ៉េត និង អៀង សារី នៅចាំទទួលសម្ដេច សីហនុ ដែរ។

នៅក្នុងខែមករា ឆ្នាំ១៩៧៦ ក្រោយពីមានកិច្ចប្រជុំសភារបស់ខ្មែរក្រហម និងបន្ទាប់ពីបានតែងតាំងប៉ុល ពត ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមជានាយករដ្ឋមន្ត្រីទី១របស់កម្ពុជាប្រជាធិបតេយ្យរួច ខ្ញុំត្រូវបានគេបញ្ជូនឲ្យទៅកាន់កន្លែងចាស់របស់ខ្ញុំ គឺនៅភាគឦសានប្រទេស ក្នុងខេត្តរតនៈគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះវិញ។ ក្នុងរយៈពេលនៃការស្នាក់នៅរបស់ខ្ញុំប៉ុន្មានឆ្នាំនោះ ខ្ញុំបានទៅដល់ផ្លូវលំហូជីមិញ និងបានឆ្លងកាត់តំបន់ សៀមប៉ាង វើនសៃ និងអូរយ៉ាដាវ។ នៅចុងឆ្នាំ១៩៧៨ ក្នុងជួរកងទ័ពរបស់ខ្ញុំម្នាក់ៗភិតភ័យគ្រប់គ្នា ព្រោះសង្កេតឃើញថាឲ្យតែមានលិខិតអញ្ជើញឲ្យទៅចូលរួមប្រជុំនៅ



លោក ចាន់ អិន មេឃុំព្រៃផ្ដៅ បានរំឭកអំពីប្រវត្តិធ្លាប់ធ្វើជាទាហានខ្មែរក្រហមប្រាប់ដល់ប្រជាជនក្នុងភូមិ ក្រោយពេលដែលគាត់បានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទីក្រុងភ្នំពេញ គឺដឹងតែបាត់ខ្លួនរហូតហើយ។ មេៗរបស់ខ្ញុំដែលបានទៅតាមការអញ្ជើញ គឺអត់មាននរណាម្នាក់វិលត្រឡប់មកអង្គភាពវិញទេ។ ខ្ញុំក៏ភ័យខ្លួននឹងគេដែរ ព្រោះគ្រួសាររបស់ខ្ញុំសុទ្ធតែជាអ្នកមានពីសង្គម។ ខ្ញុំបារម្ភពីសុខទុក្ខរបស់ឪពុកម្តាយខ្ញុំណាស់។ ខ្ញុំបានចូលរួមប្រយុទ្ធជាមួយសត្រូវជាច្រើនលើកច្រើនសារនៅក្នុងឆ្នាំ១៩៧៨។ នៅសមរភូមិចុងក្រោយ ខ្ញុំត្រូវគ្រាប់បាក់កដៃខាងឆ្វេង។ យុទ្ធមិត្តរួមក្រុម បានបញ្ជូនខ្ញុំចេញពីសមរភូមិ ហើយខ្ញុំត្រូវបានបញ្ជូនមកព្យាបាលរបួសនៅក្នុងមន្ទីរពេទ្យមួយកន្លែង (ភ្លេចឈ្មោះ) រហូតជាសះស្បើយ។ បន្ទាប់មក ខ្ញុំបានវិលត្រឡប់ទៅកាន់មូលដ្ឋានទ័ពរបស់ខ្ញុំវិញ ហើយបន្តប្រយុទ្ធប្រឆាំងជាមួយកងទ័ពសត្រូវរហូតបាក់ទ័ព រត់បោលសមរភូមិ។ ខ្ញុំ និងយុទ្ធមិត្តប៉ុន្មាននាក់ទៀត បានរត់ទៅដល់ខេត្តព្រះវិហារ និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ មិត្តខ្ញុំខ្លះ បានរត់ឆ្ពោះទៅកាន់តំបន់អន្លង់វែង។ ចំណែកខ្ញុំបានវិលត្រឡប់មកកាន់ខេត្តសៀមរាប ហើយខ្ញុំបានចូលសារភាពនៅទីនោះ។ ខ្ញុំបានមកដល់ផ្ទះខ្ញុំឯស្រុកកំណើតវិញនៅក្រោយឆ្នាំ១៩៧៩ ពេលដែលខ្ញុំមានអាយុ២៣ឆ្នាំ។ ខ្ញុំបានចំណាយពេល៩៦ថ្ងៃ សម្រាប់ការធ្វើដំណើរដោយថ្មើរជើងពីភាគឦសានប្រទេស មកដល់ស្រុកកំណើត ដោយឆ្លងកាត់ខេត្តព្រះវិហារ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦។

ដូច្នេះអ្វីដែលខ្ញុំបានរៀបរាប់ខាងលើនេះ គឺជាប្រវត្តិរបស់ខ្ញុំ ហើយក៏ជាកសិណសាក្សី ដែលធ្លាប់បម្រើការងារក្នុងជួរកងទ័ពខ្មែរក្រហម ដើម្បីបុព្វហេតុជាតិមាតុភូមិតាមការអំពាវនាវពីសម្តេចឪឲ្យរួមកម្លាំងជាមួយខ្មែរក្រហម ដើម្បីរំដោះប្រទេសឲ្យរួចផុតពីការត្រួតត្រារបស់ លន់ នល់ ដែលបានធ្វើរដ្ឋប្រហារដោយខុសច្បាប់ទម្លាក់សម្តេចព្រះនរោត្តម សីហនុ។ ពេលដែលខ្ញុំបានឃើញ និងបានអានសៀវភៅនេះ ខ្ញុំសូមអរព្រះគុណដល់សម្តេចម៉ែដែលលោកគឺជាសាក្សីប្រវត្តិសាស្ត្រពិតៗ ដែលបានរៀបរាប់ពីហេតុការណ៍ដែលបានកើតឡើងចំពោះព្រះអង្គមុនពេលរបបខ្មែរក្រហម ហើយនៅពេលនេះ បងប្អូនប្រជាពលរដ្ឋរបស់ព្រះអង្គ បានដឹងហើយពីភាពលំបាករបស់ព្រះអង្គ ដើម្បីស្វែងរកសុខសន្តិភាពឲ្យកូនចៅ និងប្រទេសជាតិរបស់ព្រះអង្គ។ ប៉ុន្តែអ្វីដែលធ្វើឲ្យប្រជាជនខកចិត្តបំផុតនេះគឺ ក្រោយខែមករា ឆ្នាំ១៩៧៦ ស្រាប់តែបាត់ដំណឹង និងលែងឮសូរឈ្មោះ ព្រមទាំងលែងឃើញព្រះភ័ក្ត្រសម្តេចព្រះ នរោត្តម សីហនុ តែម្តង។ បើកុំតែបានលោកគ្រូមានប្រសាសន៍ពីការជាប់ឃុំឃាំងរបស់សម្តេចព្រះនរោត្តម សីហនុ ក្នុងរបបខ្មែរក្រហម ម្ល៉េះសមខ្ញុំនិងបងប្អូនឯទៀត នៅតែមិនបានដឹងពីទុក្ខលំបាករបស់ព្រះអង្គឡើយ។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅឃុំព្រៃផ្តៅ កំពុងអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សចំនួន១៥០នាក់ នៃវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប ទទួលបាន សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះ មហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

**ទូច វណ្ណាត**



នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួន១៥០ក្បាលដល់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់១១ នៅវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប ស្ថិតនៅឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួន១៥០ក្បាលដល់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ ១១ នៅវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប ស្ថិតនៅឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម។ ការចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះ ធ្វើឡើងតបតាមការស្នើសុំរបស់គណៈគ្រប់គ្រងវិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សង្កើប សម្រាប់តម្រូវការក្នុងការសិក្សា និងស្រាវជ្រាវរបស់សិស្សានុសិស្ស ទាក់ទងនឹងប្រវត្តិសាស្ត្រដ៏មានសារសំខាន់របស់ប្រទេសកម្ពុជា។

ជាកិច្ចចាប់ផ្ដើម លោក ឆេង ម៉ាប់ នាយករងវិទ្យាល័យ សម្ដេចតេជោ ហ៊ុនសែនសង្កើប ថ្លែងអំណរ

គុណដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានចំណាយពេលវេលាចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដល់សិស្សានុសិស្សដើម្បីសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជា និងសម្រាប់តម្កល់នៅបណ្ណាល័យរបស់វិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប។

តមក លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ធ្វើការណែនាំខ្លួន និងសមាជិកក្រុមរួមមាន ទូច វណ្ណេត, សាំង ចាន់ធូ និង លី ដេវីត។ ឆ្លៀតឱកាសនោះ លោក ស៊ាង ចិន្តា បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្ស និងពន្យល់អំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរសម្រាប់សិស្សានុសិស្ស ដែលជាក្មេងជំនាន់ក្រោយ ធ្វើការសិក្សាឈ្វេងយល់ចេញពីព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ យាងមកកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣។

បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» សិស្សានុសិស្សចំណាយរយៈពេល២០នាទីដើម្បីបើកមើល ហើយខណៈនោះ សិស្សឈ្មោះ ធន វីរៈ អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១១ ផ្នែកវិទ្យាសាស្ត្រសង្គម ត្រូវបានស្នើឲ្យក្រោកឈរ និងអានត្រង់ទំព័រទី៦៧ ដែលបង្ហាញអំពី កាលបរិច្ឆេទ ៖ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៣។ បន្ទាប់មក វីរៈ សង្ខេបថា ៖ «អ្វីដែលហ្លួនម៉ែលើកឡើងនៅទំព័រនេះ គឺបង្ហាញថា ថ្ងៃទី១៨ ខែមីនា កាលពី៣ឆ្នាំមុន លន់ នល់ បានធ្វើរដ្ឋប្រហារ ដែលបណ្តាលឲ្យមានការបាត់បង់សន្តិភាព និងធ្វើឲ្យប្រជាជនទទួលរងទុក្ខវេទនាចេញពីការផ្ទុះឡើងនូវភ្លើងសង្គ្រាម»។

ការចែករំលែកចំណេះដឹងប្រវត្តិសាស្ត្រតាមរយៈការអានសៀវភៅ របស់ វីរៈ ត្រង់ទំព័រទី៦៧ នេះ គឺធ្វើឡើងដើម្បីបណ្តុះការចង់ដឹង និងការចង់អានទៅកាន់សិស្សានុសិស្សផ្សេងទៀត ដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។







នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យហ្លួនម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួន១៥០ក្បាលដល់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១១ នៅវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន សង្កើប ស្ថិតនៅឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់

## ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ពញាក្រែក

ទី ស៊ីថា



នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៣០៥ក្បាល ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យ ហ៊ុន សែន ពញាក្រែក ស្ថិតនៅភូមិពោធិស្រុក ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៩:០០នាទីព្រឹក ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើដំណើរទៅដល់វិទ្យាល័យ ហ៊ុន សែន ពញាក្រែក ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៣០៥ក្បាល ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។

ជាកិច្ចចាប់ផ្តើមកម្មវិធីលោក ជា សឿង នាយករងវិទ្យាល័យ ហ៊ុន សែន ពញាក្រែក បានឡើងថ្លែងមតិស្វាគមន៍ និងសម្តែងនូវសេចក្តីរីករាយដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម អញ្ជើញមកដល់វិទ្យាល័យ ហ៊ុន សែន ពញាក្រែក ព្រមទាំងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅថ្ងៃនេះ។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានឡើងណែនាំខ្លួន និងក្រុមការងារ ព្រមទាំងថ្លែងអំណរគុណដល់គណៈគ្រប់គ្រងសាលា

លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សចំពោះការទទួលស្វាគមន៍ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មៗ ឆ្លៀតឱកាសនោះ លោក ឡុង ដានី សង្ខេបខ្លីអំពី មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ និងមានទីតាំងស្ថិតនៅក្នុងសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្មៗ ការបើកដំណើរការមជ្ឈមណ្ឌលឯកសារកោះថ្ម មានគោលបំណងសំខាន់ៗដូចខាងក្រោម ៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០ៗ

២) ពង្រឹងការកសាងសន្តិភាព និងទប់ស្កាត់ជម្លោះតាមរយៈកម្មវិធីអប់រំ ព្រមទាំងផ្តល់ជាឱកាសសម្រាប់យុវជនរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងការចូលរួមៗ

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យចែករំលែក និងបង្រៀនក្មេងៗនូវបទពិសោធន៍របស់ពួកគាត់ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមៗ

៤) ប្រមែប្រមូលចងក្រងរឿងរ៉ាវបទពិសោធន៍ពីអ្នករស់រានមានជីវិតដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមៗ

៥) ជួយសម្របសម្រួលលើគម្រោង«លើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តត្បូងឃ្មុំៗ

លោក ឡុង ដានី បានបន្ថែមថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ គឺជាព្រះរាជសំណេរដើម និងមិនបានកែសម្រួលដោយឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់សម្តេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព និងសេចក្តីថ្លៃថ្នូរ ក្នុងអំឡុងពេលដែលព្រះអង្គអមព្រះរាជដំណើរ សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ យាងដំណើរតាមយន្តហោះចេញពីទីក្រុងប៉េកាំងទៅកាន់ទីក្រុងហាណូយ និងទីក្រុងដុងហូយ ខេត្តក័ងបិញ ប្រទេសវៀតណាម និងយាងបន្តដោយរថយន្តតាមបណ្តោយផ្លូវលំហូជីមិញទៅកាន់ខេត្តសៀមរាបប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៣ៗ ព្រះរាជដំណើររបស់ព្រះអង្គទាំងទ្វេត្រូវចំណាយពេលជាងមួយខែនេះ បានបង្ហាញយ៉ាងច្រើនអំពីសេចក្តីថ្លៃថ្នូរ និងភាពទន់ភ្លន់របស់ព្រះមហាក្សត្រី ទោះជាព្រះរាជដំណើររបស់ព្រះអង្គស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជា

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៣០៥ក្បាល ជូនលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យ ហ៊ុន សែន ពញាក្រែក ស្ថិតនៅភូមិពោធិស្រុក ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





និងតំបន់អាស៊ីអាគ្នេយ៍នាពេលនោះក្តី។ ព្រះមហាក្សត្រ គឺជាសាក្សីផ្ទាល់ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងរយៈកាលជាង៧ទសវត្សរ៍កន្លងមក ហើយព្រះអង្គគឺជាតស្សូរជនប្រវត្តិសាស្ត្រដ៏លេចធ្លោមួយក្នុងអំឡុងពេលនោះ។

នៅក្នុងឱកាសនោះ លោក ជុន សុខន គ្រូបង្រៀនប្រវត្តិវិទ្យានៃវិទ្យាល័យ ហ៊ុន សែន ពញាក្រែក បានឡើងផ្តាំផ្ញើដល់ប្អូនៗសិស្សានុសិស្សទាំងអស់ដែលបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ថា សូមប្អូនៗយកសៀវភៅនេះទៅអានទាំងអស់គ្នា ហើយដល់ម៉ោងខ្ញុំបង្រៀន ខ្ញុំនឹងសួរសំណួរទាក់ទងនឹងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលអញ្ជើញមកចែកសៀវភៅនៅវិទ្យាល័យខ្ញុំ និងសូមជូនពរឲ្យក្រុមការងារទទួលបានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។

បន្ទាប់មក សិស្សានុសិស្សនៃវិទ្យាល័យ ហ៊ុន សែន ពញាក្រែក បង្ហាញនូវចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **សា រិទ្ធារ៉ា** គឺជាសិស្សវិទ្យាល័យ ហ៊ុន សែន ពញាក្រែក។ ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំងដែលបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ខ្ញុំនឹងខិតខំរៀនសូត្រ ស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរដើម្បីទទួលបានចំណេះដឹងកាន់តែច្រើន និងយកទៅចែករំលែកដល់ប្អូនៗជំនាន់ក្រោយ។

ខ្ញុំឈ្មោះ **វុទ្ធី ទិកា** អាយុ១៦ឆ្នាំ រស់នៅភូមិកោងកាង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ថ្ងៃនេះជាលើកដំបូងដែលខ្ញុំទទួលបានសៀវភៅ «សាក្សីប្រវត្តសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលបានរៀបរាប់អំពីដំណើរជីវិតរបស់ហ្លួងម៉ែ អំឡុងពេលព្រះអង្គអមព្រះរាជដំណើរសម្តេចព្រះនរោត្តម សីហនុ យាងមក កាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣។ ខ្ញុំពិតជាត្រេកអរខ្លាំងណាស់ពេលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ព្រោះសៀវភៅនេះបានប្រាប់អំពីព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រកម្ពុជាសំខាន់ៗ។ សៀវភៅនេះ ក៏ជាជំនួយក្នុងការសិក្សារៀនសូត្របន្ថែមរបស់ខ្ញុំដែរ។

ខ្ញុំឈ្មោះ **ប៉ុង ពុយ** អាយុ១៦ឆ្នាំ។ ខ្ញុំមានអារម្មណ៍រីករាយនៅពេលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ខ្ញុំនឹងព្យាយាមសិក្សាឈ្វេងយល់ស្រាវជ្រាវបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាចេញពីសៀវភៅដ៏សំខាន់នេះ និងផ្សព្វផ្សាយទៅដល់សិស្សានុសិស្សជំនាន់ក្រោយឲ្យបានយល់ដឹងអំពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។





នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៣០៥ក្បាល ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យ ហ៊ុន សែន ពញាក្រែក ស្ថិតនៅភូមិពោធិ៍ស្រុក ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

## កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស វិទ្យាល័យ តាលោ

**ចាន់ ណារិទ្ធ និង ធី គីមហុង**



នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២៨០ក្បាល ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យ តាលោ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៧សៀល ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានធ្វើដំណើរមកដល់វិទ្យាល័យតាលោ ស្ថិតនៅក្នុងឃុំតាលោ ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ចំនួន ២៨០នាក់។

ជាកិច្ចចាប់ផ្តើមលោក តេង ធា នាយកវិទ្យាល័យ តាលោ បានថ្លែងអរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលនាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលទើបតែបោះពុម្ពថ្មី មកចែកជូនដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យតាលោ នាឱកាសនេះ។ លោក តេង ធា បានផ្តាំផ្ញើទៅប្អូនៗសិស្សានុសិស្សទាំងអស់ត្រូវអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ

របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នេះឲ្យចប់ ព្រោះវានឹងជួយប្អូនៗ បានយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ជាពិសេសអំពីប្រវត្តិរបស់សម្តេចយាយទួត និងសម្តេចតាទួតរបស់យើងទាំងអស់គ្នា។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ឡើងថ្លែងអំណរគុណដល់លោកនាយក លោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សានុសិស្សដែលបានអញ្ជើញមកចូលរួមក្នុងកម្មវិធីនៅថ្ងៃនេះ។ ឆ្លៀតឱកាសនោះ លោក ឡុង ដានី បានជម្រាបជូនលោកគ្រូអ្នកគ្រូនិងសិស្សានុសិស្សអំពីមជ្ឈមណ្ឌលផ្សះផ្សាវាលវែងដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ដែលមានទីតាំងស្ថិតនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងគោលបំណង ដូចតទៅ ៖ ១) ផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៩០ ដែលនៅអំឡុងពេលនោះប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ ២) ពង្រឹងសន្តិភាពតាមរយៈការអប់រំ និងផ្តល់ឱកាសឲ្យក្មេងៗជំនាន់ក្រោយបានសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដល់កូនចៅជំនាន់ក្រោយ ៤) បន្តចងក្រងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមស្រាវជ្រាវ និងចងក្រងទីតាំងឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ និង ៥) ជួយសម្របសម្រួលលើកគម្រោង «លើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ចុងក្រោយ លោក ឡុង ដានី លើកឡើងអំពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើសុំព្រះរាជានុញ្ញាតពីព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ តាំងពី១២ឆ្នាំមុនដើម្បីបោះពុម្ព ប៉ុន្តែទ្រង់ទើបតែសព្វព្រះរាជហឫទ័យអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពផ្សាយជាផ្លូវការនៅពេលថ្មីៗនេះ។ សៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» គឺជាព្រះរាជសំណេរដើម ដោយមិនមានការកែសម្រួល ហើយបានឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់ហ្លួងម៉ែផ្ទាល់។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» រៀបរាប់អំពីព្រះរាជដំណើរសម្តេចព្រះ នរោត្តម សីហនុ យាងមកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣ ដោយចេញព្រះរាជដំណើរពីទីក្រុងប៉េកាំងមកទីក្រុងហាណូយ និងបន្តតាមផ្លូវលំហូជីមិញមកកាន់ប្រទេសកម្ពុជា។ ក្នុងរយៈពេល៣៩ថ្ងៃនៃព្រះរាជដំណើរ ហ្លួងម៉ែបានសរសេរកំណត់ហេតុជារៀងរាល់ថ្ងៃ ព្រមទាំងបង្ហាញឲ្យឃើញពីភាពទន់ភ្លន់ និងសេចក្តីថ្លៃថ្នូររបស់ព្រះអង្គ ទោះបីស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងចលាចលក៏ដោយ។ «សៀវភៅសាក្សីប្រវត្តិសាស្ត្រ» គឺជាចំណែកប្រវត្តិ-សាស្ត្រមួយយ៉ាងសំខាន់ សម្រាប់ប្អូនៗជាពិសេសប្អូនៗដែលសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីពង្រឹងចំណេះដឹង និងសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ។







នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២៤០ក្បាល ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅវិទ្យាល័យ តាលោ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖
## កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស វិទ្យាល័យ ជា ស៊ីម កណ្តាលជ្រុំ

**ឌី ស៊ីថា**



នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២៨៣ក្បាល ជូនលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស វិទ្យាល័យ ជា ស៊ីម កណ្តាលជ្រុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៩:៣០នាទីព្រឹក ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើដំណើរមកដល់វិទ្យាល័យ ជា ស៊ីម កណ្តាលជ្រុំ ស្ថិតនៅក្នុងភូមិកណ្តាលជ្រុំ ឃុំកណ្តាលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២៨៣ក្បាល ជូនលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ជាកិច្ចចាប់ផ្តើមលោក ជិន ឡុង់ឌី នាយកវិទ្យាល័យ ជា ស៊ីម កណ្តាលជ្រុំ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក ឡុង ដានី និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកវិទ្យាល័យ ជា ស៊ីម

កណ្ដាលជ្រុំ ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលទើបតែបោះពុម្ពថ្មី និងជាសៀវភៅដ៏មានតម្លៃពិសេសសម្រាប់ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ វិទ្យាល័យ ជា ស៊ីម កណ្ដាលជ្រុំ មានលោកគ្រូ អ្នកគ្រូ ចំនួន៦៣នាក់ ក្នុងនោះមានស្រី២៨នាក់ និងសិស្សានុសិស្សចំនួន១៣១៧ នាក់ ក្នុងនោះមានស្រី៧២៨នាក់។ លោក ជិន ឡុងឌី បន្តថា កន្លងមកខ្ញុំធ្លាប់តែឃើញសៀវភៅផ្សេងៗ ទាក់ទងនឹងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅថ្ងៃនេះខ្ញុំបានទទួលសៀវភៅថ្មីមួយទៀត គឺសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុរបស់ហ្វូងម៉ែ ក្នុងព្រះរាជដំណើរមកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣។ ខ្ញុំមិនដែលបានដឹងពីព្រះរាជដំណើររបស់ព្រះអង្គមកកាន់ប្រទេសកម្ពុជា អំឡុងពេលប្រទេសកម្ពុជាកំពុងមានសង្គ្រាមស៊ីវិល ព្រមទាំងមានការបែងចែករវាងប្លុកកុម្មុយនីស្ត និងសេរីនោះទេ។ លោក ជិន ឡុងឌី បានលើកឡើងថា ប្អូនៗសិស្សានុសិស្សត្រូវតែការពារសន្តិភាពតាមរយៈការអប់រំ និងការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរ។ ប្រសិនបើចំណុចណាល្អប្អូនៗត្រូវទទួលយក ប៉ុន្តែបើចំណុចណាមិនល្អ ត្រូវបោះបង់ចោល។ ម្យ៉ាងទៀត ប្អូនៗអាចអភិវឌ្ឍន៍ប្រទេសជាតិទៅតាមចំណេះដឹង និងសមត្ថភាពដែលប្អូនៗធ្លាប់បានរៀនសូត្រ។

បន្ទាប់មក លោក ឡុង ដានី ឡើងសម្ដែងការអរគុណដល់លោកនាយក លោកគ្រូ អ្នកគ្រូ និងប្អូនៗ សិស្សានុសិស្ស ដែលបានអញ្ជើញមកចូលរួមពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងថ្ងៃនេះ។ តមក លោក ឡុង ដានី បានធ្វើការណែនាំពីមជ្ឈមណ្ឌលឯកសារកោះថ្មដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្នុងគោលបំណងដូចខាងក្រោម៖

១) ផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីឆ្នាំ១៩៦០ ដល់ ឆ្នាំ១៩៩០ អំឡុងពេលដែលប្រទេសកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍។

២) ពង្រឹងសន្តិភាពតាមរយៈការអប់រំ ផ្ដល់ឱកាសឲ្យក្មេងៗជំនាន់ក្រោយ បានសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម។






នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២៨៣ក្បាល ជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស វិទ្យាល័យ ជា ស៊ីម កណ្ដាលជ្រុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៣) លើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដល់កូនចៅជំនាន់ក្រោយ។

៤) មជ្ឈមណ្ឌលឯកសារកោះថ្ម នៅតែបន្តចងក្រងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរ ក្រហម និងស្រាវជ្រាវចងក្រងអំពីទីតាំងឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម(១៩៧៥-១៩៧៩)។

៥) សម្របសម្រួលលើកគម្រោងសុខភាពបន្ទាប់ពីអ្នកស្ម័គ្រចិត្តកម្ពុជា បានចុះសួរសុខទុក្ខ, បញ្ហាសុខភាព និងរឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាចុងក្រោយលោក ឡុង ដានី បានលើកឡើងថា ចំពោះសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងព្រះរាជដំណើរអមសម្តេចព្រះនរោត្តម សីហនុ យាងមកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើសុំព្រះរាជានុញ្ញាតពីសម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរតាំងពី១២ឆ្នាំមុន ប៉ុន្តែទ្រង់ទើបតែសព្វព្រះរាជហឫទ័យអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពផ្សាយជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពព្រះរាជសំណេរដើមរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដោយមិនបានកែសម្រួល និងបានឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់ហ្លួងម៉ែផ្ទាល់។

សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាព្រះរាជកំណត់ហេតុរបស់ហ្លួងម៉ែ ដែលអមព្រះរាជដំណើរសម្តេចព្រះ នរោត្តម សីហនុ មកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣ ដោយចេញព្រះរាជដំណើរពីទីក្រុងប៉េកាំង មកទីក្រុងហាណូយ និងបន្តតាមផ្លូវលំហូជីមិញមកកាន់ប្រទេសកម្ពុជា។ ក្នុងរយៈពេល៣៩ថ្ងៃនៃព្រះរាជដំណើរនេះ ហ្លួងម៉ែបានសរសេរកំណត់ហេតុរៀងរាល់ថ្ងៃ ហើយបានបង្ហាញអំពីភាពទន់ភ្លន់ និងសេចក្តីថ្លៃថ្នូររបស់ព្រះអង្គ ទោះជាស្ថានភាពនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ស្ថិតក្នុងភាពចលាចលក៏ដោយ។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាចំណែកប្រវត្តិសាស្ត្រដ៏សំខាន់សម្រាប់សិស្សានុសិស្ស ជាពិសេស អ្នកដែលសិក្សាស្រាវជ្រាវដើម្បីពង្រីកនូវចំណេះដឹង និងសមត្ថភាព។

នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២៨៣ក្បាល ជូនលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស វិទ្យាល័យ ជា ស៊ីម កណ្តោលជ្រុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ជូនសិស្សានុសិស្សវិទ្យាល័យព្រែកដំបូក

ទូច វណ្ណាក និង សាំង ចាន់ធូ



នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សថ្នាក់ទី១១ ចំនួន៥០នាក់មកពីវិទ្យាល័យព្រែកដំបូក។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សាស្តីអំពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សថ្នាក់ទី១១ ចំនួន៥០នាក់មកពីវិទ្យាល័យព្រែកដំបូក។ ដើម្បីជំរុញដល់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក៏ដូចជាផ្តល់ឱកាសដល់សិស្សានុសិស្សដែលជាយុវជនដើម្បីឈ្វេងយល់អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ទើបមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានរៀបចំដំណើរទស្សនកិច្ចសិក្សានេះឡើង ដោយបានដាក់បញ្ចូលកម្មវិធីសិក្សាមួយចំនួនរួមមាន៖ ការចុះទៅទីតាំងប្រវត្តិសាស្ត្រ, ស្តូបរំឭកសម្រាប់សហគមន៍, ទីតាំងសម្លាប់ក្នុងរបបខ្មែរក្រហម, ការចុះទៅកាន់ទំនប់ខ្មែរក្រហម និង

ការចុះជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ចំណែកវត្តរកាគយ អតីតសមរភូមិក្តៅរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ក៏ជាទីតាំងដំបូងដែលសិស្សានុសិស្សចុះមកទស្សនកិច្ចសិក្សា។

នៅក្នុងឱកាសនោះ លោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានដឹកនាំការពិភាក្សាទៅលើប្រធានបទ ៖ ការផ្ទុះឡើងសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ លោក លី ដេវីត បន្តថា មិនយូរប៉ុន្មានបន្ទាប់ពីរដ្ឋប្រហារ លន់ នល់ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង។ នៅចុងឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិសាស្ត្រនានានៅក្នុងខេត្តកំពង់ចាម។ ទាហាន លន់ នល់ បានប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែកនៅភូមិសាស្ត្រណាដែលមានវត្តមានកងទ័ពរំដោះខ្មែរក្រហមឈរជើង និងបញ្ជូនទាហានថ្មើរជើងមកឈរជើងនៅទីតាំងដែលកងទ័ពខ្មែរក្រហមដកចេញ។ ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះឡើងទាំងផ្លូវគោក និងផ្លូវទឹក។ ចាប់ពីឆ្នាំ១៩៧៣ ទាហាន លន់ នល់ ត្រូវបានដកមកឈរជើងនៅព្រំប្រទល់ទីរួមខេត្តកំពង់ចាម ដើម្បីត្រៀមប្រយុទ្ធតទល់ជាមួយកងទ័ពរំដោះខ្មែរក្រហមដែលកំពុងតែឡោមព័ទ្ធជុំវិញ។ ទាហាន លន់ នល់ ប្រើប្រាស់ផ្លូវទឹកតាមដងទន្លេមេគង្គក្នុងការដឹកជញ្ជូនសម្ភារ និងស្បៀងចូលទៅទីរួមខេត្តកំពង់ចាម។ កងទ័ពរំដោះខ្មែរក្រហមតែងតែបើកការវាយប្រហារលើទាហាន លន់ នល់ ដោយបានបណ្តែតគ្រាប់បែកបង្កែកាត់ទន្លេ និងបាញ់ចេញពីច្រាំងទន្លេ។ កងទ័ពរំដោះខ្មែរក្រហមធ្វើសង្គ្រាមផ្លូវទឹកជាមួយទាហានជើងទឹក (ម៉ារីន) លន់ នល់ រហូតដល់ឆ្នាំ១៩៧៥។ វត្តរកាគយគឺជាទីតាំងដែលនាវាចម្បាំងទាហាន លន់ នល់ និងក្បួននាវា





នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សថ្នាក់ទី១១ ចំនួន៥០នាក់មកពីវិទ្យាល័យព្រែកដំបូក។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដឹកសម្ភារផ្សេងៗបើកឆ្លងកាត់ និងតែងតែទទួលរងការបាញ់ និងវាយប្រហារពីត្រើយទាំងសងខាងនៃទន្លេមេគង្គ និងការបណ្តែតគ្រាប់បែកតាមដើមចេកពីសំណាក់កងទ័ពរំដោះខ្មែរក្រហម។

ទីតាំងបន្ទាប់គឺស្តូបរំឭកសម្រាប់សហគមន៍នៅឃុំគគរ ដែលសិស្សានុសិស្សចុះទៅដល់។ ការចុះទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍នៅឃុំគគរ គឺដឹកនាំដោយ លោក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយអាចសួរនាំទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

អំពីបទពិសោធន៍ និងបង្កើនការចង់ដឹងអំពីរឿងរ៉ាវកើតឡើងក្នុងមូលដ្ឋានក្នុងរបបខ្មែរក្រហម។

លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានជួបសន្ទនាផ្ទាល់ជាមួយសិស្សានុសិស្ស និងប្រាប់អំពីគោលបំណងនៃការសាងសង់ស្តូបរំឭកសម្រាប់សហគមន៍នេះ គឺដើម្បីរំឭកដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងការនិយាយប្រាប់បទពិសោធន៍របស់អ្នករស់រានមានជីវិតទៅកាន់ក្មេងជំនាន់ក្រោយ។ បន្ទាប់មកសិស្សានុសិស្សទាំងអស់ធ្វើដំណើរទៅកាន់ទំនប់៩កុម្ភៈ ស្ថិតនៅភូមិថ្នល់បែកកើត ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ ទំនប់៩កុម្ភៈត្រូវបានចាប់សាងសង់ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដើម្បីស្តុកទឹកទុកប្រើប្រាស់ និងបញ្ចូលស្រែនៅរដូវប្រាំង។ ប្រជាជនត្រូវបានចល័តមកលើកទំនប់ និងទទួលរងការធ្វើការងារហួសកម្លាំង គ្មានអាហារហូបគ្រប់គ្រាន់ និងធ្លាក់ខ្លួនឈឺគ្មានថ្នាំព្យាបាល។

ជាកិច្ចបញ្ចប់នៃដំណើរទស្សនកិច្ចសិក្សានេះ សិស្សានុសិស្សទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ម្នាក់មួយក្បាលពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដើម្បីទុកប្រើប្រាស់ជាឯកសារប្រវត្តិ-សាស្ត្រផ្ទាល់ខ្លួន និងសិក្សាឈ្វេងយល់អំពីបរិបទប្រវត្តិសាស្ត្រកម្ពុជា។

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សថ្នាក់ទី១១ ចំនួន៥០នាក់មកពីវិទ្យាល័យព្រែកដំបូក។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )











# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
## រៀបចំកម្មវិធីទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» សម្រាប់សិស្សវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ

**មេក ឌិន**



នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» សម្រាប់សិស្សានុសិស្សចំនួន៤១នាក់មកពីវិទ្យាល័យ ហ៊ុន សែនឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំកម្មវិធីទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» សម្រាប់សិស្សានុសិស្សចំនួន៤១នាក់មកពីវិទ្យាល័យ ហ៊ុន សែនឧត្តរមានជ័យ។ ទស្សនកិច្ចសិក្សានេះធ្វើឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងផ្នែកប្រវត្តិសាស្ត្រដល់យុវជន ការកសាងសន្តិភាព និងការផ្សះផ្សា។

មុនពេលចូលរួមដំណើរទស្សនកិច្ចសិក្សានេះ សិស្សឈ្មោះ ថៃ ស៊ីកលី មានវ័យ១៨ឆ្នាំ បាននិយាយថា ខ្ញុំធ្លាប់បានឮអំពីស្រុកអន្លង់វែងដែលមានទីតាំងប្រវត្តិសាស្ត្រជាច្រើនបន្សល់ទុកពីរបបខ្មែរក្រហម។ ប៉ុន្តែខ្ញុំមិនដែលបានស្គាល់ឬឃើញទីតាំងប្រវត្តិសាស្ត្រទាំងនោះទេ។ ចំណែក ឡេ ករុណា គឺជាសិស្សវិទ្យាល័យ ហ៊ុន សែនឧត្តរមានជ័យ បានដឹងខ្លះៗអំពីអន្លង់វែង ដែលជាតំបន់ប្រវត្តិសាស្ត្រ។ អន្លង់វែងគឺជាសហគមន៍មួយដែលបានបន្សល់ទុកកេរដំណែលនៃការតស៊ូរបស់ក្រុមខ្មែរក្រហម។ ខ្ញុំបានដឹងថា ប៉ុល ពត បានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។



នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» សម្រាប់សិស្សានុសិស្សចំនួន៤១នាក់មកពីវិទ្យាល័យ ហ៊ុន សែនឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បើយោងតាមសៀវភៅ «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងតំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម» ៖ សៀវភៅណែនាំសម្រាប់មគ្គុទេសក៍ទេសចរណ៍បានសរសេរថា «អន្លង់វែងធ្លាប់ជាស្រុកដ៏ស្ងាត់ជ្រងំ មានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រតិចតួចបើគិតត្រឹមឆ្នាំ១៩៧៩។ ក្រោយឆ្នាំ១៩៧៩ ជាពិសេសក្រោយឆ្នាំ១៩៨៩ នៅពេលដែលកងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា តំបន់នៅជុំវិញអន្លង់វែងក៏មានភាពលេចធ្លោឡើង និងក្លាយជាតំបន់តស៊ូដ៏សំខាន់មួយរបស់ខ្មែរក្រហម»។

នៅក្នុងឱកាសនោះ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើការសម្របសម្រួល និងធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្សដោយផ្តោតសំខាន់ទៅលើកិច្ចការងាររបស់មជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែង បានអនុវត្តកន្លងមកជាពិសេស លើកយកនូវបរិបទប្រវត្តិសាស្ត្រជុំវិញការកកើតរបបខ្មែរក្រហម សោកនាដកម្មក្រោមអំពើឃោរឃៅ និងការបិទបញ្ចប់នូវទំព័រប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។

ភាពយន្តឯកសារស្តីពីមន្ទីរ ស-២១ ឬ គុកទួលស្លែង ក៏ត្រូវបានចាក់បញ្ចាំងជូនសិស្សានុសិស្សបានទស្សនា និងឈ្វេងយល់បន្ថែមពីការធ្វើទារុណកម្មអ្នកទោសដែលជាប់ឃុំឃាំងនៅទីនោះ។

បន្ទាប់ពីបានទស្សនាកុនឯកសារមន្ទីរ ស-២១ រួចមកសិស្សានុសិស្សក៏បានសម្តែងនូវអារម្មណ៍រន្ធត់និងសោកសៅ នៅពេលបានឃើញទិដ្ឋភាពអ្នកទោសដេកស្លាប់នៅក្នុងបន្ទប់ដោយជើងនិងដៃជាប់ខ្នោះ ហើយអ្នកខ្លះទៀតមានការសម្លាប់ដោយវះពោះ និងអារក។ បន្ថែមលើនេះ បណ្ឌិត លី សុខឃាង ក៏បានលើកយកនូវ «ទស្សនាវដ្តីស្វែងរកការពិត» មកសិក្សាបន្ថែមដោយផ្តោតសំខាន់ទៅលើផ្នែកទី១ «ពិភពលោកអន្លង់វែង» ដើម្បីឲ្យសិស្សានុសិស្សបានឈ្វេងយល់កាន់តែច្បាស់ពីភូមិសាស្ត្រ ក៏ដូចជាប្រវត្តិ-សាស្ត្ររបស់អន្លង់វែង។

បន្ទាប់ពីការធ្វើបទបង្ហាញ ក្រុមការងារមជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែងបានដឹកនាំសិស្សានុសិស្ស



នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និង សិទ្ធិមនុស្ស» សម្រាប់សិស្សានុសិស្ស ចំនួន៤១នាក់មកពីវិទ្យាល័យ ហ៊ុន សែនឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅទស្សនាពិព័រណ៍ស្តីអំពី«សង្គ្រាមនិងអំពើប្រល័យពូជសាសន៍» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើខ្នងភ្នំដងរែក ព្រមទាំងទស្សនាទីតាំងប្រវត្តិសាស្ត្រមួយចំនួនទៀត ដូចជា ទីតាំងបូជាសព ប៉ុល ពត, ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ, ចេតិយ តាម៉ុក និងសារមន្ទីរតាម៉ុក ដើម្បីសិក្សាស្វែងយល់បន្ថែម។







# ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ជួបប្រជុំពិភាក្សាជាមួយអភិបាលនិងអភិបាលរង ស្រុកជើងព្រៃ អំពីការជួយផលិតវីដេអូសមិទ្ធផលនានា ក្នុងស្រុកជើងព្រៃ

**សាំង ចាន់ធូ**



នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានជួបប្រជុំជាមួយលោក ជិន ហ៊ិ អភិបាលរងនៃគណៈអភិបាលស្រុកជើងព្រៃ ដើម្បីពិភាក្សាអំពីការជួយផលិតជាវីដេអូសមិទ្ធផលនានាក្នុងស្រុកជើងព្រៃ និងការរៀបចំតូបពិព័រណ៌របស់រដ្ឋបាលស្រុកជើងព្រៃ ក្នុងទិវាសពិធីប្រណាំងទូក នៅថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០២៣។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំដោយលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានជួបប្រជុំជាមួយលោក ជិន ហ៊ិ គឺជាអភិបាលរងស្រុកជើងព្រៃ ដើម្បីពិភាក្សាអំពីការជួយផលិតជាវីដេអូសមិទ្ធផលនានា និងការរៀបចំតូបតាំងពិព័រណ៌របស់រដ្ឋបាលស្រុកជើងព្រៃ ក្នុងទិវាសពិធីប្រណាំងទូកងប្រភេទខ្នាតខ្លី (ទូក-ខ) ទូកខ្នាតអន្តរជាតិ និងតាំងពិព័រណ៌សមិទ្ធផលរដ្ឋបាលក្រុង-ស្រុក មន្ទីរ អង្គភាពជុំវិញខេត្ត ដែលនឹងរៀបចំឡើងដោយរដ្ឋបាលខេត្តកំពង់ចាម នៅថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០២៣។ បន្ទាប់ពីកិច្ចប្រជុំបានបញ្ចប់ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមក៏បានទៅជួបសម្តែងការគួរជាមួយលោក អ៊ូត ឈាង លី អភិបាលនៃគណៈអភិបាលស្រុកជើងព្រៃ។

នៅចុងបញ្ចប់នៃការប្រជុំពិភាក្សា រដ្ឋបាលស្រុកជើងព្រៃ បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌល

ឯកសារខេត្តកំពង់ចាម ក្នុងការផ្តល់កិច្ចសហការ រៀបចំពិព័រណ៍ និងការផលិតវីដេអូ ក៏ដូចជាជួយឧបត្ថម្ភសម្ភារដល់ទូកដែលចូលរួមប្រណាំង។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានជួបប្រជុំជាមួយលោក ជិន ហ៊ អភិបាលរងនៃគណៈអភិបាលស្រុកជើងព្រៃ ដើម្បីពិភាក្សាអំពីការជួយផលិតជាវីដេអូសមិទ្ធផលនានាក្នុងស្រុកជើងព្រៃ និងការរៀបចំតូបពិព័រណ៍របស់រដ្ឋបាលស្រុកជើងព្រៃ ក្នុងឱកាសពិធីប្រណាំងទូក នៅថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០២៣។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )








# វគ្គបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ក្រោមប្រធានបទ

## «ការពង្រឹងភាពជាអ្នកដឹកនាំក្នុងដំណើរការសកម្មភាពការងារជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»

ថុន ស្រីពេជ្រ



អ្នកស្ម័គ្រចិត្តចំនួន៩២នាក់ ក្នុងនោះមានស្រី៥៨នាក់ ត្រូវបានជ្រើសរើសចេញពីស្រុកពារាំង ស្រុកមេសាង ស្រុកកំចាយមារ និងស្រុកពាមរក៍ មកចូលរួមវគ្គបណ្តុះបណ្តាល កាលពីថ្ងៃទី៦ និងទី៧ ខែតុលា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្នុងគោលបំណងបង្កើននូវចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងគន្លឹះសំខាន់មួយចំនួន ក្នុងការអនុវត្តសកម្មភាពការងារនៅតាមមូលដ្ឋាន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់អទិភាពដល់យុវជនជំនាន់ក្រោយ ក្រោមអាយុ២៥ឆ្នាំ ឲ្យធ្វើកិច្ចការការងារស្ម័គ្រចិត្តដើម្បីជំនួយដល់កិច្ចការងារសង្គម តាមរយៈការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការសិក្សាស្រាវជ្រាវអំពីបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកស្ម័គ្រចិត្តចំនួន៩២នាក់ ក្នុងនោះមានស្រី៥៨នាក់ ត្រូវបានជ្រើសរើសចេញពីស្រុកពារាំង ស្រុកមេសាង ស្រុកកំចាយមារ និងស្រុកពាមរក៍ មកចូលរួមវគ្គបណ្តុះបណ្តាល កាលពីថ្ងៃទី៦ និងទី៧ ខែតុលា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្នុងគោលបំណងបង្កើននូវចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងគន្លឹះសំខាន់មួយចំនួនក្នុងការអនុវត្តសកម្មភាពការងារនៅតាមមូលដ្ឋាន។ វគ្គបណ្តុះបណ្តាលចំនួន២ថ្ងៃនេះ គឺផ្តោតសំខាន់ទៅលើ «ការពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំក្នុងដំណើរការអនុវត្តសកម្មភាពការងារជាមួយអ្នក

រស់រានមានជីវិតពីរបបខ្មែរក្រហម។ ការបំពេញកម្រងសំណួរ ស្តីអំពីការវាយតម្លៃបុគ្គលិកលក្ខណៈរបស់អ្នកស្ម័គ្រចិត្ត។ ផ្សាភ្ជាប់ទៅនឹងប្រធានបទខាងលើ អ្នកស្ម័គ្រចិត្តទាំងអស់តម្រូវឲ្យបំពេញនូវកម្រងសំណួរវាស់ស្ទង់សមត្ថភាព និងភាពជាអ្នកដឹកនាំរបស់អ្នកស្ម័គ្រចិត្ត ក្នុងការបំពេញភារកិច្ចជាអ្នកស្ម័គ្រចិត្តកម្ពុជា នៃមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ការបំពេញនូវកម្រងសំណួរនេះនឹងជួយដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្នុងការវាយតម្លៃ ថាតើអ្នកស្ម័គ្រចិត្តអាចធ្វើការក្នុងគម្រោងបានដែរឬយ៉ាងណា។ វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនេះបានជំរុញឲ្យសិស្ស-និស្សិតមានភាពជឿជាក់លើសមត្ថភាពខ្លួនឯង ព្រមទាំងបណ្តុះឲ្យអ្នកស្ម័គ្រចិត្តនូវការតាំងចិត្ត ការប្តេជ្ញាចិត្ត ការប្រាកដប្រជា និងមានទំនួលខុសត្រូវខ្ពស់ចំពោះការងារ។ បន្ថែមពីលើនេះ អ្នកស្ម័គ្រចិត្តបានយល់ដឹងអំពីតម្លៃនៃការងារស្ម័គ្រចិត្ត និងតម្លៃនៃការជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាដំបូង លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានណែនាំខ្លួន និងគម្រោងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចំពោះអ្នកស្ម័គ្រចិត្តទាំងអស់ដែលត្រូវអនុវត្ត គឺគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។ លោកបានលើកទឹកចិត្តឲ្យអ្នកស្ម័គ្រចិត្តទាំងអស់អានសៀវភៅណែនាំអំពីការថែទាំសុខភាព និងជំងឺទាំង១០ប្រភេទដែលកើតមានចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានប្រគល់ជូនដើម្បីយកទៅចែករំលែក និងផ្សព្វផ្សាយព័ត៌មានស្តីអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អំឡុងពេលដែលពុំមានវេជ្ជបណ្ឌិតនៅក្បែរ។ បន្ថែមពីលើផ្នែកសុខភាព លោក ផេង ពង្សរ៉ាស៊ី ក៏ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ការសិក្សាពីគោលនយោបាយ៨ចំណុចរបស់ខ្មែរក្រហម សម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជា ក្នុងការយល់ដឹងនូវប្រវត្តិសាស្ត្ររបស់ខ្លួន និងបានផ្តល់ជាគំនិតបន្ថែមក្នុងការធ្វើបទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតនៅតាមមូលដ្ឋាន។ ការធ្វើបទបង្ហាញនេះបានធ្វើឲ្យអ្នកស្ម័គ្រចិត្តមានការយល់ដឹងពីទុក្ខលំបាករបស់ប្រជាជនខ្មែរក្នុងរបបខ្មែរក្រហម។

ដំណើរការអនុវត្តកិច្ចការគម្រោងឬការចុះទៅសម្ភាសន៍អ្នកភូមិ អ្នកស្ម័គ្រចិត្តកម្ពុជា ទទួលបាននូវវិធីសាស្ត្រល្អៗមួយចំនួនដូចជា ១) ការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ២) ការត្រៀមលក្ខណៈសម្បត្តិ ទាំងផ្នែកសម្ភារ និងការរៀបចំខ្លួនឲ្យមានឥរិយាបថល្អដើម្បីចុះទៅសម្ភាសន៍ ៣) វិធីសាស្ត្រសម្ភាសន៍ ៤) វិធីសាស្ត្រសង្ខេប និង៥) វិធីសាស្ត្រក្នុងការបញ្ជូនឯកសារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។ វិធីសាស្ត្រដែលបានបង្ហាញខាងលើ គឺអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់មុនធ្លាប់អនុវត្តរួចហើយពេលចុះទៅសម្ភាសន៍អ្នកភូមិរួមមាន៖ ការថតរូប, ការថតវីដេអូ, ការថតសំឡេង និងការសង្ខេបរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ចុងក្រោយលោក ផេង ពង្សរ៉ាស៊ី បង្រៀនអ្នកស្ម័គ្រចិត្តកម្ពុជាដោយផ្ទាល់ពីរបៀបប្រើទូរស័ព្ទដៃដើម្បីរក្សាទុកឯកសារ និងការបញ្ជូនឯកសារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។

អ្នកស្ម័គ្រចិត្តមានការសប្បាយរីករាយជាខ្លាំងនៅពេលដែលបានមកចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ ជាពិសេសគឺចំណេះដឹងថ្មីចំពោះកិច្ចការងារស្ម័គ្រចិត្ត។ អ្នកស្ម័គ្រចិត្តនឹងជួបមនុស្សថ្មី ធ្វើឲ្យពួកគាត់មានភាពក្លាហាន និងបង្កើតទំនាក់ទំនងល្អជាមួយមនុស្សដែលខ្លួនពុំធ្លាប់បានជួបគ្នាពីមុនមក។ អំឡុងពេលសិក្សារៀនសូត្រ អ្នកស្ម័គ្រចិត្តភាគច្រើនជាពិសេសអ្នកស្ម័គ្រចិត្តដែលកំពុងរៀននៅវិទ្យាល័យ បានបង្ហាញពីការយកចិត្តទុកដាក់ទៅលើវគ្គបណ្តុះបណ្តាល ជាពិសេសគឺរបៀបនៃការសម្ភាសន៍ និងការសរសេរសេចក្តីសង្ខេបរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកស្ម័គ្រចិត្តមានការរំពឹងថា នៅពេលដែលពួកគាត់ចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ពួកគាត់នឹងទទួលបាននូវចំណេះដឹងថ្មីបន្ថែមទៀតពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីជំនួយដល់ការប្រឡងសញ្ញាបត្រទុតិយភូមិនៅថ្ងៃខាងមុខ។

ក្រោយពីបានចូលរួមវគ្គបណ្តុះបណ្តាល អ្នកស្ម័គ្រចិត្តបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

**សេន ពន្លឺ អាយុ២៥ឆ្នាំ រស់នៅភូមិស្លាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង**

បន្ទាប់ពីបានចូលរៀនវគ្គបណ្តុះបណ្តាលពេញមួយថ្ងៃមក ខ្ញុំទទួលបានចំណេះដឹងថ្មីជាច្រើន ដូចជា ការប្រើប្រាស់សំណួរដែលត្រូវសួរទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការប្រាស្រ័យទាក់ទងជាមួយ តា យាយចាស់ៗ ការសង្ខេបរឿងរ៉ាវ ការថតសំឡេង និងការផ្ញើឯកសារទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំយល់ថាកម្មវិធីបណ្តុះបណ្តាលនេះ ពិតជាល្អសម្រាប់សហគមន៍ក្មេងជំនាន់ក្រោយរួមទាំងអ្នកស្ម័គ្រចិត្តកម្ពុជា។ ចំណែកការងារស្ម័គ្រចិត្ត គឺបានជួយដល់តាយាយដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលបាននូវភាពកក់ក្តៅបន្ទាប់ពីបានផ្តល់បទសម្ភាស៍រួចៗ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយល់ថា ទោះបីយ៉ាងណាក្មេងៗជំនាន់ក្រោយនៅតែយកចិត្តទុកដាក់ និងខ្វល់ខ្វាយចំពោះគាត់ ដោយមិនទុកគាត់ចោលឲ្យនៅឯកាឡើយ បន្ទាប់ពីគាត់ឆ្លងកាត់សម័យកាលដ៏ជូរចត់។

**ទ្រី ឡៃអ៊ី ភេទស្រី អាយុ១៦ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុនសែន ពាមរក៍**

នៅថ្ងៃនេះ ខ្ញុំសិក្សាឈ្វេងយល់អំពីកិច្ចការងារស្ម័គ្រចិត្តមួយចំនួន ដូចជា ចេះទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន វិធីសាស្ត្រក្នុងការជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចេះសួរសំណួរពេលដែលចុះទៅសម្ភាសន៍មានឥរិយាបថល្អអំឡុងពេលជួបចាស់ទុំ រៀបចំសម្ភារសម្រាប់សម្ភាសន៍ឲ្យបានគ្រប់ចំនួន ដូចជា ត្រៀមទូរសព្ទដើម្បីថតសំឡេង សៀវភៅដើម្បីកត់ត្រា និងចុងក្រោយគឺរបៀបនៃការរក្សាទុកឯកសារឲ្យបានត្រឹមត្រូវ។

**ហោ ចាន់ថេន ភេទប្រុស មានអាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុនសែន ពាមរក៍**

សម្រាប់វគ្គបណ្តុះបណ្តាលនេះ ខ្ញុំទទួលបានចំណេះដឹងជាច្រើន ដូចជា បានយល់ដឹងពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានទទួលការអប់រំទូន្មានប្រៀនប្រដៅពីលោកគ្រូ ចេះគោរព និងមានឥរិយាបថល្អចំពោះចាស់ទុំ។ ខ្ញុំគិតថាកម្មវិធីនេះបានជួយជំរុញឲ្យសិស្សខិតខំសិក្សាស្រាវជ្រាវរកសាក្សីប្រវត្តិសាស្ត្រ ដើម្បីចងក្រងទុកជាឯកសារសម្រាប់កូនចៅជំនាន់ក្រោយៗ។ មួយវិញទៀត គម្រោង «ការលើកកម្ពស់សិទ្ធិនិងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នឹងជួយដល់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម។

**ណើម ស្រីណែត ភេទស្រី អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុនសែន ពាមរក៍**

ខ្ញុំពិតជាសប្បាយរីករាយ នៅពេលដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលថ្ងៃនេះ។ ខ្ញុំទទួលបាននូវចំណេះដឹងថ្មីៗជាច្រើនរួមមាន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ខ្ញុំនឹងខិតខំប្រឹងប្រែងព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីធ្វើកិច្ចការងារស្ម័គ្រចិត្តឲ្យបានល្អ។





អ្នកស្ម័គ្រចិត្តចំនួន៩២នាក់ ក្នុងនោះមានស្រី៥៨នាក់ ត្រូវបានជ្រើសរើសចេញពីស្រុកពារាំង ស្រុកមេសាង ស្រុកកំចាយមារ និងស្រុកពាមរក៍ មកចូលរួមវគ្គបណ្តុះបណ្តាល កាលពីថ្ងៃទី៦ និងទី៧ ខែតុលា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្នុងគោលបំណងបង្កើននូវចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងគន្លឹះសំខាន់មួយចំនួន ក្នុងការអនុវត្តសកម្មភាពការងារនៅតាមមូលដ្ឋាន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិទី១០

**សាំង ចាន់ធូ**

នៅចន្លោះពីថ្ងៃទី២ ដល់ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលដឹកនាំដោយលោក សាំង ចាន់ធូ ប្រធានក្រុមការងារអ្នកស្ម័គ្រចិត្រកម្ពុជាប្រចាំខេត្តកំពង់ចាម បានចុះធ្វើការសម្ភាសន៍អំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងភូមិទី៨ និងភូមិទី១០ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខាងក្រោម គឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ៖



ឡាយ ស៊ីឡេក
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ឡាយ ស៊ីឡេក អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិទី១០ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ ឡាយ ស៊ីឡេក មានប្តីឈ្មោះ ជឹម ម៉េង និងមានកូនស្រីម្នាក់។ សព្វថ្ងៃ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានឪពុកឈ្មោះ សេង ឡាង និងម្តាយឈ្មោះ ស៊ុន អាយ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៣នាក់ គឺប្រុស២នាក់និងស្រីម្នាក់ (ខ្ញុំ)។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រទេ ដោយសារប្រទេសជាតិមានសង្គ្រាមៗ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ឪពុករបស់ខ្ញុំនាំប្រពន្ធកូនចាកចេញពីផ្ទះ ទៅរស់នៅភូមិដ្យេផ។ នៅឆ្នាំ១៩៧១ មានកងទ័ពរំដោះខ្មែរក្រហមបានចូលមកនៅតាមភូមិលាយ ឡុំជាមួយប្រជាជនជាបណ្តើរៗ។ នៅឆ្នាំ១៩៧២ កងទ័ព លន់ នល់ ចាប់ផ្តើមទម្លាក់គ្រាប់បែក ពេលនោះខ្ញុំរត់ទៅនៅដីហែបានរយៈពេល៣ទៅ៤ខែ ក៏ផ្លាស់ទៅនៅភូមិមហាលាភវិញ។ នៅឆ្នាំ១៩៧៣ ដោយសារតែសង្គ្រាមនៅតែបន្ត ឪពុកខ្ញុំបាននាំកូនៗទៅនៅភូមិបឹងព្រួល ពាមជីលាំង បានរយៈពេល៤ខែ រួចក៏ឆ្លងទូកមកនៅកោះកំពង់ត្រុំទាំងយប់ៗ នៅឆ្នាំ១៩៧៤ ឪពុកខ្ញុំបាននាំកូនៗត្រឡប់មកស្រុកកំណើតវិញ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមជម្លៀសគ្រួសារ

ខ្ញុំតាម ទូកទៅពាមជីកង។ ខ្ញុំដេកនៅព្រៃចេករយៈពេល២០ថ្ងៃនៅពាមជីកង ទើបអ្នកបើកឡានមកដឹកគ្រួសារខ្ញុំទៅស្រុកតាំងគោក។ ពេលទៅដល់តាំងគោក ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យប្រូតស្រូវក្នុងការដ្ឋានស្នែងទងស្ថិតនៅសង្កាត់ស្វាយភ្លើង ស្រុកតាំងគោក ខេត្តកំពង់ធំ។ បន្ទាប់មក ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅវែកដី និងលើកទំនប់ ចាប់ពីម៉ោង៦ដល់ម៉ោង១១ព្រឹក ទើបអាចសម្រាកហូបបាយលាយពោត។ នៅឆ្នាំ១៩៧៦ ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ដោយចោទថា គាត់ធ្វើពេទ្យពីសង្គមចាស់។ ប្អូនរបស់ខ្ញុំក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងប្តី និងប្រពន្ធមានផ្ទៃពោះ៧ខែដែរ ដោយពេលដែលខ្មែរក្រហមយកទៅសម្លាប់នោះ ខ្មែរក្រហមកុហកថាផ្លាស់ទីលំនៅថ្មី។ នៅឆ្នាំ១៩៧៧ អង្គការឲ្យខ្ញុំវែកដីនៅកំពង់ត្របែកដែលមានគ្នាចំនួន១០០នាក់។ ខ្ញុំក្រោកពីម៉ោង៥ទៀបភ្លឺដើរទៅប្រជុំជួររួចបំបែកគ្នាទៅធ្វើការតាមផែនការថ្នាក់លើដាក់ឲ្យ។ ពេលនោះ ខ្ញុំត្រូវចូលកងចល័តពិសេស ដូច្នេះខ្មែរក្រហមបានចែកខោអាវពណ៌ខ្មៅ ក្រមាពណ៌ខៀវ និងស្បែកជើងកង់ឡានឲ្យខ្ញុំ។ ខ្ញុំធ្វើការនៅពេលយប់ហើយចន្លោះពីម៉ោង៨ ទៅម៉ោង៩ ខ្ញុំដើរវាយកណ្តុរ។ នៅឆ្នាំ១៩៧៩ ទើបខ្ញុំត្រឡប់មកស្រុកកំណើតវិញ។

**វ៉ាន គីមលាវ អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិទី១០ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម**

ខ្ញុំឈ្មោះ វ៉ាន គីមលាវ ។ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំមានអាយុប្រមាណ៣០ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនចំនួន៨នាក់។ កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេ។ ខ្ញុំបានរៀបការព្រមទាំងមានកូនចំនួន៣នាក់ គឺប្រុស២នាក់ និងស្រី១នាក់។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមចូលគ្រប់គ្រង ខ្ញុំមិនត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទេ។ រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការងារជាក្រុម រួមមានពេលព្រឹកវែកដី បន្ទាប់មក កិនពោតជាន់អង្កររហូតដល់ម៉ោង១១យប់ទើបបានសម្រាក។ នៅវេលាម៉ោង៤ទៀបភ្លឺ ប្រធានក្រុមដាស់ខ្ញុំឲ្យក្រោកឡើងទៅតម្រង់ជួរ ហើយម៉ោង៥ ខ្ញុំត្រូវកាន់បង្គី ដើរតម្រង់ជួរទៅវែកដី ចំណែករបបអាហារគឺមានតែបបររាវៗ។ នៅសម័យនោះ ទោះបីខ្ញុំឃ្លានយ៉ាងណាក៏មិនហានលួចដែរ។ សូម្បីតែដំណាំដែលខ្ញុំដាំខ្លួនឯងក៏ដោយ ក៏ខ្ញុំមិនហ៊ានហូបដែរ ខ្លាចអង្គការយកទៅសម្លាប់ ឬធ្វើបាប។ នៅក្នុងរបបខ្មែរក្រហម ឪពុករបស់ខ្ញុំមានតួនាទីជាអ្នកធ្វើម្ហូបនៅរោងបាយ ចំណែកខ្ញុំជាអ្នកមើលថែក្មេងតូចៗ។ នៅសម័យនោះ ខ្មែរក្រហមចាប់ប្អូនៗរបស់ខ្ញុំបួននាក់យកទៅសម្លាប់ចោល។



វ៉ាន គីមលាវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បឹងកេងកង បុគ្គលិក ... 















# មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស សម្រាប់សិស្សានុសិស្សវិទ្យាល័យពាមជាំង

សុភ័ក្រ្ត ភាណា







នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន៥៣នាក់ មកពីវិទ្យាល័យ ពាមជាំង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ទទួលស្វាគមន៍សិស្សានុសិស្សចំនួន៥៣នាក់ មកពីវិទ្យាល័យពាមជាំង ដែលមកចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស។ វេទិកាថ្នាក់រៀននេះ មានគោលបំណងបំពាក់បំប៉នដល់សិស្សានុសិស្សនូវចំណេះដឹងផ្នែកប្រវត្តិសាស្ត្រជាពិសេស ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដើម្បីលើកកម្ពស់ការត្រិះរិះពិចារណាដោយប្រើប្រាស់មេរៀនប្រវត្តិសាស្ត្រ។

មុនពេលចាប់ផ្តើមវេទិកាថ្នាក់រៀន សិស្សានុសិស្ស ត្រូវបំពេញកម្រងសំណួរស្ទាបស្ទង់ចំណេះដឹងជាមុនដើម្បីវាស់ស្ទង់ចំណេះដឹងរបស់ខ្លួនទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ឡើងធ្វើបទបង្ហាញខ្លីអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរក្រហម អមជាមួយផ្ទាំងពិព័រណ៌រូបភាព





ប្រវត្តិសាស្ត្រ ដែលដាក់តាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្មៗ ពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញទាំងនេះ រួមបញ្ចូលនូវរូបភាពក្នុងអំឡុងពីមុន និងក្រោយរបបខ្មែរក្រហមៗ បន្ទាប់ពីបានស្តាប់ការពន្យល់ បកស្រាយអំពីផ្ទាំងពិព័រណ៍រូបថត សិស្សានុសិស្ស ទស្សនាភាពយន្តឯកសារក្រោមចំណងជើងថា «ដំណើរឆ្ពោះទៅរកការសង្គ្រោះជាតិ»ៗ

កម្មវិធីបន្ទាប់ គឺអ្នកស្រី សុភ័ក្រ្ត ភាណា ប្រធានគម្រោងស្រាវជ្រាវភាសាចិននៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញអំពីទំនាក់ទំនងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយសង្ខេបៗ ឆ្លៀតឱកាសនោះ អ្នកស្រី សុភ័ក្រ្ត ភាណា បានស្នើឲ្យសិស្សានុសិស្ស២រូប អានប្រវត្តិរូបសង្ខេបរបស់មេដឹកនាំខ្មែរក្រហម និងទំនាក់ទំនងការបរទេសរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសដទៃទៀតៗ តមក សិស្សានុសិស្សត្រូវបំពេញកម្រងសំណួររង្វាស់ស្ទង់ចំណេះដឹងក្រោយវេទិកាថ្នាក់រៀនៗ

នៅចុងបញ្ចប់កម្មវិធីវេទិកាថ្នាក់រៀន ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានចែកសៀវភៅដែលទើបបោះពុម្ពថ្មី ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនសិស្សានុសិស្សដើម្បីអាន និងឈ្វេងយល់ពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាបន្ថែមៗ



នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សិស្សានុសិស្ស ចំនួន៥៣នាក់ មកពីវិទ្យាល័យ ពាមជាំង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្មៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ចារថ្មី ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីសារសំខាន់នៃ

## ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងធ្វើទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ិច-១៦

ឈុំ រ៉ា







នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ិច-១៦ ដល់សិស្សវិទ្យាល័យ ហ៊ុន សែន ចារថ្មី ចំនួន២៦នាក់ ក្នុងនោះមានសិស្សស្រី១៥នាក់ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ិច-១៦ ដល់សិស្សវិទ្យាល័យ ហ៊ុនសែនចារថ្មីចំនួន២៦នាក់ ក្នុងនោះមានសិស្សស្រី១៥នាក់ៗ

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានដឹកនាំសិស្សានុ-សិស្សដើរទស្សនាពិព័រណ៍រូបថតអំពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០, រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩), រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩, រូបថតអំពីកស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបប

ខ្មែរក្រហម (១៩៧៥-១៩៧៩), រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូបទៀតទៅប្រទេសវៀតណាម កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។

បន្ទាប់មកលោក ឡុង ដានី បានធ្វើបទបង្ហាញដល់សិស្សានុសិស្សអំពីអំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ វត្ថុបំណងនៃការបង្រៀនអំពីអំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះគឺមានដូចខាងក្រោម ៖

១) ចង់ឲ្យសិស្សានុសិស្សយល់ដឹងខ្លះៗអំពីខ្លឹមសារក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជដំណើររបស់ហ្លួងម៉ែ និងសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ យាងមកប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៧៣។

២) បង្ហាញពីភាពទន់ភ្លន់ និងសេចក្តីថ្លៃថ្នូររបស់ហ្លួងម៉ែ ចំពោះព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនរបស់ហ្លួងម៉ែ ក្នុងព្រះរាជដំណើរចេញពីទីក្រុងប៉េកាំងមកទីក្រុងហាណូយ រួចហើយបន្តព្រះរាជដំណើរដោយរថយន្តតាមផ្លូវលំហូជីមិញចូលមកប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៧៣។

៣) ចង់ឲ្យសិស្សានុសិស្សឈ្វេងយល់ពីរបៀបសរសេរ និងសារសំខាន់នៃកំណត់ហេតុផ្ទាល់ខ្លួន។

លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញជាសង្ខេបអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០១ និង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមមាន៖

ទី១) សំណុំរឿង០០១៖ ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ដែលប្រជាជនកម្ពុជាទូទៅបានស្គាល់ថាជាគុកទួលស្លែងស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ នៅឆ្នាំ២០១២ ឌុច ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។

ទី២) សំណុំរឿង០០២ ៖ នៅឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប រួមមាន៖ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ដោយសារភាពស្មុគស្មាញនៃរឿងក្តី និងអាយុរបស់ជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចបំបែកសំណុំរឿង០០២ ជាពីរគឺ សំណុំរឿង០០២ វគ្គ១ និងសំណុំរឿង០០២ វគ្គ២ សម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា ដោយសារ អៀង សារី និង អៀង ធិរិទ្ធ មានជំងឺ និងទទួលមរណភាពនៅឆ្នាំ២០១៣ និង២០១៥។ ដូច្នេះ នៅឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោស នួន ជា និង ខៀវ សំផនឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការសម្លាប់ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាលទីពីរនៃការផ្លាស់ប្តូរទីលំនៅប្រជាជន។ សំណុំរឿង០០២ វគ្គ២ គឺជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍, ការដ្ឋានការងារ, មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងក្រុមមនុស្សដែលជាក្រុមគោលដៅជាក់លាក់ ដូចជាជនជាតិចាម, ជនជាតិវៀតណាម, អ្នកកាន់ព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹង

មនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ នៅឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយសារជរាភាព។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចផ្តន្ទាទោស ខៀវ សំផនឲ្យជាប់ពន្ធនាគារអស់មួយជីវិតបន្ថែមទៀត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មខាងលើ និងបានបិទបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែម្តង។

ឆ្លៀតឱកាសនោះ លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីមូលហេតុនៃការកើតឡើងអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ហើយនៅចុងបញ្ចប់នៃកម្មវិធីវេទិកាថ្នាក់រៀន ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំសិស្សានុសិស្សទៅទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ុច-១៦។

បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម សិស្សានុសិស្សបង្ហាញនូវចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **ខាំ សំណាញ** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យ ហ៊ុន សែន ចារថ្មី។ ថ្ងៃនេះខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ដែលបានមកចូលរួមវេទិកាថ្នាក់រៀន និងទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ព្រមទាំងទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួនមួយក្បាល។ តាមរយៈការអានសៀវភៅនេះធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជា នៅក្នុងឆ្នាំ១៩៧៣ ដែលបានបង្ហាញអំពីកក្តីភាពរបស់សម្តេចយាយ និងសម្តេចតា ចំពោះប្រទេសជាតិ និងហ៊ានពលិកម្មដើម្បីយាងព្រះរាជដំណើរមកមាតុភូមិកម្ពុជា។ ខ្ញុំក៏ដឹងអំពីសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជានៅអំឡុងពេលនោះដែរ។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ពិតជាមានសារសំខាន់ព្រោះអាចឲ្យខ្ញុំដឹងអំពីប្រវត្តិសាស្ត្រពិត និងផ្តល់ចំណេះដឹងឲ្យខ្ញុំដើម្បីយកទៅអភិវឌ្ឍន៍ប្រទេសជាតិឲ្យបានល្អប្រសើរ។

ខ្ញុំឈ្មោះ **ខាត់ ស្រីកា** ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ចារថ្មី។ ខ្ញុំពិតជាសប្បាយរីករាយ និងត្រេកអរខ្លាំងណាស់ដែលបានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ បន្ទាប់ពីអានសៀវ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចែកឲ្យ ធ្វើឲ្យខ្ញុំកាន់តែយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជា។ បន្ថែមលើនេះ ខ្ញុំក៏ទទួលបានចំណេះជាច្រើនពីគ្រូឧទ្ទេសដែលធ្វើបទបង្ហាញអំពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» និងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្ញុំសូមជូនពរក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មទាំងអស់មានសុខភាពល្អ និងទទួលជោគជ័យគ្រប់ភារកិច្ច។







នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ុច-១៦ ដល់សិស្សវិទ្យាល័យ ហ៊ុន សែន ចារថ្មី ចំនួន២៦នាក់ ក្នុងនោះមានសិស្សស្រី១៥នាក់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យក្រាំងស្វា ចូលរួមវេទិកាថ្នាក់រៀន
## ចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា

រឹម ស្រីស្រស់ និង ចាន់ ទីន







នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន៤០នាក់មកពីវិទ្យាល័យក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ មកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅសល់រយៈពេលត្រឹមតែ១៦ថ្ងៃទៀតប៉ុណ្ណោះ សិស្សានុសិស្សថ្នាក់ទី១២ទាំងអស់នឹងត្រូវចូលរួមប្រឡងថ្នាក់ជាតិបញ្ចប់ការសិក្សាទុតិយភូមិ។ ដូច្នេះដើម្បីបានឈ្វេងយល់ឲ្យកាន់តែច្បាស់ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម សិស្សានុសិស្សវិទ្យាល័យ ក្រាំងស្វា បានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ បើកវគ្គបំប៉នដល់ពួកគាត់អំពីមាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន៤០នាក់មកពីវិទ្យាល័យក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ បានមកកាន់មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ដើម្បីទទួលបានការពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ គោលបំណងសំខាន់បំផុតក្នុងការរៀបចំវេទិកានេះឡើងគឺមិនត្រឹមតែផ្តល់លទ្ធភាពដល់យុវជនជំនាន់ក្រោយឲ្យឈ្វេងយល់កាន់តែស៊ីជម្រៅពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់ការរិះរកវិធីសាស្ត្រទប់ស្កាត់ដើម្បីកុំឲ្យរបបនេះកើតឡើងជាលើកទីពីរ។

ដើម្បីបម្រើដល់គោលបំណងដូចបានរៀបរាប់ខាងលើ វេទិកាថ្នាក់រៀននេះ អនុវត្តតាមរបៀប

ការៈ សំខាន់ៗចំនួន៣ចំណុចគឺ ៖ ទី១) ផ្ដល់ចំណេះដឹងបន្ថែម ទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទី២) ពិភាក្សាអំពីវិធានការនានាដើម្បីទប់ស្កាត់ការវិលត្រឡប់នៃរបបខ្មែរក្រហម និង ទី៣) បំផុសស្មារតីឲ្យសិស្សានុសិស្សចេះអត់ឱន និងអធ្យាស្រ័យគ្នា។

ជាដំបូង សិស្សានុសិស្ស បានទស្សនាផ្ទាំងពិព័រណ៍រូបថតពីព្រឹត្តិការណ៍ដែលកើតឡើងក្នុងរបបខ្មែរក្រហមដែលបានតាំងបង្ហាញ នៅផ្នែកខាងមុខការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ បន្ទាប់មក សិស្សានុសិស្សទាំងអស់ចាប់ផ្ដើមបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងដែលមានស្រាប់របស់ខ្លួនទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។

តមក លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានណែនាំខ្លួន និងប្រាប់អំពីចក្ខុវិស័យនៃការបង្កើតមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ មុនចាប់ផ្ដើមធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្ត្រក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ លោក ដេង ពង្សរ៉ាស៊ី បានលើកជាសំណួរ «តើប្អូនបានដឹងអ្វីខ្លះពីរបបខ្មែរក្រហម?» ទៅកាន់អ្នកចូលរួមទាំងអស់ដើម្បីចង់ដឹងពីចំណេះដឹងពីមុនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ការបំផុសសំណួរនេះ គឺដើម្បីនាំអ្នកចូលរួមទាំងអស់ឲ្យផ្ដោតសំខាន់លើប្រធានបទ។ បន្ទាប់មក លោក ដេង ពង្សរ៉ាស៊ី បានលើកឡើងនូវសំណួរមួយទៀត «តើប្អូនៗចង់ដឹងអ្វីខ្លះទៀតពីរបបខ្មែរក្រហម?»។ សំណួរនេះ បានផ្ដល់ឲ្យសិស្សានុសិស្សនូវឱកាសក្នុងការដោះស្រាយចម្ងល់របស់ខ្លួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលខ្លួនមានតាំងពីយូរមកហើយ ដែលមិនទាន់ត្រូវបានដោះស្រាយ។

ខាងក្រោមនេះ គឺជាចម្ងល់របស់អ្នកចូលរួមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ៖

១) តើហេតុអ្វីបានជា ប៉ុល ពត ប្រកាន់យកលទ្ធិជ្រុលនិយម។

២) តើនរណាខ្លះគឺជាមេដឹកនាំខ្មែរក្រហម?

៣) តើមូលហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមបង្ខំប្រជាជនឲ្យធ្វើការគ្មានពេលឈប់សម្រាក និងកាប់សម្លាប់ប្រជាជនយ៉ាងព្រៃផ្សៃ?

៤) តើមូលហេតុអ្វីបានជារបបខ្មែរក្រហមកើតឡើងនៅប្រទេសកម្ពុជា?

៥) នៅពេលខ្មែរក្រហមឡើងកាន់អំណាចបានផ្ដល់ផលប៉ះពាល់អ្វីខ្លះ?

៦) តើខ្មែរក្រហមកើតឡើងដោយសារអ្វី?

៧) តើរបបខ្មែរក្រហមមានច្បាប់ទម្លាប់ទេ?

៨) តើហេតុអ្វីបានជាប្រទេសកម្ពុជាធ្លាក់ក្នុងរបបប្រល័យពូជសាសន៍?

៩) តើរបបខ្មែរក្រហមដួលរលំដោយសារអ្វី?

១០) តើមានព្រឹត្តិការណ៍អ្វីខ្លះកើតឡើងនៅក្នុងរបបខ្មែរក្រហម?

១១) តើមានប្រទេសផ្សេងទៀតប្រព្រឹត្តដូចរបបខ្មែរក្រហមដែរឬទេ?

១២) តើគោលនយោបាយអព្យាក្រឹតមានអ្វីខ្លះ?

១៣) តើរបបខ្មែរក្រហមចេញមកពីណា?

១៤) តើបង្កើតរបបខ្មែរក្រហមឡើងដើម្បីអ្វី?

១៥ តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់អ្នកចេះដឹងដែលជាខ្មែរដូចគ្នា? តើពាក្យ «ការកសាង» និង «ការជម្លៀសប្រជាជន» មានន័យដូចម្ដេច?

១៦) តើខ្មែរក្រហមប្រព្រឹត្តអ្វីខ្លះមកលើប្រជាជន?

១៧) តើហេតុអ្វីបានជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានការគំរាមកំហែងដល់ប្រជាជន?

១៨) តើហេតុអ្វីបានជាប្រទេសមហាអំណាចមិនជួយអន្តរាគមន៍ពេលខ្មែរក្រហមកាប់សម្លាប់មនុស្ស?

១៩) តើហេតុអ្វីបានជាខ្មែរក្រហមមានសត្រូវ និងមិនត្រូវគ្នាជាមួយប្រទេសថៃ, អាមេរិក, សូវៀត និង វៀតណាម?

២០) តើហេតុអ្វីដែលជំរុញឲ្យ ប៉ុល ពត សម្លាប់មនុស្សយ៉ាងរង្គាល?

២១) ប៉ុល ពត បានបង្ខិតបង្ខំឲ្យមនុស្សធ្វើការ និងដាំស្រូវបីតោនក្នុងមួយហិកតា តើហេតុអ្វីបានជាប្រជាជនគ្មានអាហារហូប?

២២) តើ ប៉ុល ពត មានប្រវត្តិយ៉ាងណា?

២៣) តើនរណាសម្លាប់ប្រជាជន? ហេតុអ្វីបានជាមានការសម្លាប់?

២៤) តើហេតុអ្វីបានជាសង្គ្រាមវៀតណាម និងខ្មែរក្រហមឆាបឆេះឡើងនៅឆ្នាំ១៩៧៨?

២៥) តើហេតុអ្វីបានជាខ្មែរក្រហមប្រកាន់យកគោលនយោបាយ «មហាលោតផ្លោះមហាអស្ចារ្យ» សម្លាប់បញ្ញវន្ត និងប្រជាជនស្លូតត្រង់ដែលសុទ្ធតែជាជនជាតិខ្មែរដូចគ្នា?

២៦) តើហេតុអ្វីបានជា ប៉ុល ពត និងក្រុមរបស់ ប៉ុល ពត និយាយថាខ្លួនមិនបានសម្លាប់ខ្មែរ? តើវាពិតដែរឬទេ?

២៧) តើហេតុអ្វីបានជាកើតមានរបបខ្មែរក្រហម? តើនរណាគឺជាអ្នកដឹកនាំក្នុងរបបនេះ?

២៨) តើហេតុអ្វីបានជាខ្មែរក្រហមមានឱកាសឡើងកាន់អំណាច?

២៩) តើរបបខ្មែរក្រហមកៀបសង្កត់ប្រជាជនដូចម្តេចខ្លះ?

៣០) តើគោលនយោបាយរបស់ខ្មែរក្រហមដូចម្តេចខ្លះ?

សំណួរទាំងអស់ខាងលើ សិស្សានុសិស្សត្រូវកត់ត្រានៅក្នុងក្រដាសឬសៀវភៅកំណត់ហេតុរបស់ខ្លួន រួចប្រគល់ឲ្យគ្រូខុទ្ទេស ដេង ពង្សរ៉ាស៊ី ដើម្បីឆ្លើយ។ លោក ដេង ពង្សរ៉ាស៊ី មិនបានឆ្លើយសំណួរទាំងនេះភ្លាមៗទេ ព្រោះចង់ឲ្យសិស្សានុសិស្សយកចិត្តទុកដាក់ឈ្វេងយល់ពីមាតិកាប្រវត្តិសាស្ត្រសង្ខេប ដែលលោកនឹងធ្វើបទបង្ហាញនាពេលបន្តិចទៀត និងចង់ដឹងថាតើការធ្វើបទបង្ហាញនេះ ពិតជាបានឆ្លើយតបទៅនឹងសំណួរខ្លះៗហើយឬនៅ។ ដោយសារតែសិស្សានុសិស្សទាំងអស់ចង់ឈ្វេងយល់បន្ថែមពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម លោក



នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន៤០នាក់មកពីវិទ្យាល័យក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ មកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញសង្ខេបអំពីគោលការណ៍៨ចំណុចរបស់ខ្មែរក្រហម។ បន្ទាប់មកលោក ផេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារខ្លីមួយមានចំណងជើងថា «កុមារកម្ពុជា» ឲ្យសិស្សទស្សនា។ សិស្សានុសិស្សបានទស្សនាយ៉ាងយកចិត្តទុកដាក់ និងបានបង្ហាញនូវអារម្មណ៍អាណិតអាសូរទៅដល់ក្មេងៗដែលដើរដោយគ្មានគោលដៅ និងមិនមានអាហារហូបគ្រប់គ្រាន់។ នៅពេលការចាក់បញ្ចាំងត្រូវបានបញ្ចប់ លោក ផេង ពង្សរ៉ាស៊ី បានពន្យល់ពីខ្សែភាពយន្តឯកសារនេះ ទៅកាន់សិស្សានុសិស្ស។ ចុងបញ្ចប់នៃការពិភាក្សាពីមាតិកាប្រវត្តិសាស្ត្រ លោក ផេង ពង្សរ៉ាស៊ី បានដោះស្រាយរាល់ចម្ងល់ដែលសិស្សបានសួរទាំង៣០សំណួរ។

## ទស្សនកិច្ចសិក្សាទៅកាន់មន្ទីរសន្តិសុខក្រាំងតាចាន់

នៅវេលារសៀលថ្ងៃដដែល លោក ផេង ពង្សរ៉ាស៊ី បានបន្តធ្វើបទបង្ហាញអំពីនិយមន័យអំពើប្រល័យពូជសាសន៍ កត្តាគ្រោះថ្នាក់មួយចំនួនដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រសំខាន់ៗមួយចំនួនក្នុងការទប់ស្កាត់ការវិលត្រឡប់មកវិញនៃអំពើប្រល័យពូជសាសន៍។

បន្ទាប់ពីការធ្វើបទបង្ហាញនេះបញ្ចប់ទៅ លោក ផេង ពង្សរ៉ាស៊ី និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានដឹកនាំសិស្សទាំងអស់ទៅកាន់ទីតាំងឃុំឃាំង និងសម្លាប់មនុស្សនៅក្រាំងតាចាន់ ដែលបច្ចុប្បន្នជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់។ នៅទីនោះ សិស្សានុសិស្សបានទស្សនាកន្លែងជាច្រើនរាប់ទាំងកន្លែងដែលខ្មែរក្រហមនាំអ្នកទោសចូល កន្លែងឃុំឃាំង កន្លែងសម្លាប់ គុកក្រោមដី និងសារមន្ទីរតម្កល់អដ្ឋិធាតុអ្នកស្លាប់។ មុននឹងការទស្សនាកន្លែងនានាក្នុងបរិវេណមន្ទីរក្រាំងតាចាន់ លោក ផេង ពង្សរ៉ាស៊ី បានពន្យល់ណែនាំសិស្សពីដើមហេតុដែលនាំឲ្យមានការបង្កើតមន្ទីរសន្តិសុខនេះ ព្រមទាំងមូលហេតុផ្សេងៗដែលនាំឲ្យមានការឃុំឃាំង និងសម្លាប់មនុស្សនៅទីនេះ។ មុនពេលចប់កម្មវិធី សិស្សានុសិស្សបង្ហាញចំណាប់អារម្មណ៍ដូចក្រោម ៖

ខ្ញុំឈ្មោះ **ហ៊ត សៅរី** ភេទស្រី អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ ក្រាំងស្វាយ។ ថ្ងៃនេះ ខ្ញុំបានសិក្សាច្រើនទាក់ទងនឹងអំពើប្រល័យពូជសាសន៍ គោលគំនិតរបស់មេដឹកនាំខ្មែរក្រហម និងការដួលរលំនៃរបបខ្មែរក្រហម។ តាយាយរបស់ខ្ញុំធ្លាប់បាននិយាយអំពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម។ តាយាយរបស់ខ្ញុំប្រាប់ថា ពួកគាត់ធ្លាប់បានឃើញខ្មែរក្រហមបាញ់សម្លាប់ប្រជាជននៅនឹងមុខគាត់ ប៉ុន្តែគាត់មិនតវ៉ាឬប្រឆាំងខ្មែរក្រហមឡើយ។ តាមដែលនាងខ្ញុំបានរៀននៅសាលា គឺដូចទៅនឹងយាយតារបស់ខ្ញុំធ្លាប់និយាយប្រាប់។ ខ្ញុំយល់ថា វេទិកាក្នុងថ្ងៃនេះគឺល្អ ព្រោះបានផ្ដល់ចំណេះដឹងបន្ថែមទៀតបន្ទាប់ពីបានសិក្សានៅសាលារួចមក។

ខ្ញុំឈ្មោះ **ញ៉ុំ ស្រីមួយ** ភេទស្រី អាយុ១៩ឆ្នាំ មកពីវិទ្យាល័យ ក្រាំងស្វាយ។ ខ្ញុំទទួលបានចំណេះដឹងជាច្រើនពីវេទិកានេះ។ យាយតារបស់ខ្ញុំ ធ្លាប់បានប្រាប់ខ្ញុំអំពីជីវិតដែលគាត់ឆ្លងកាត់របបខ្មែរក្រហម គឺដូចដែលនាងខ្ញុំបានរៀនក្នុងថ្ងៃនេះដែរ។ ខ្ញុំបានយល់ខ្លះៗអំពីមូលហេតុដែលបណ្ដាលឲ្យមានរបបខ្មែរក្រហម និងការដួលរលំរបបខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៧៩ ពេលកំពុងមានការទម្លាក់គ្រាប់បែក ឪពុករបស់ខ្ញុំកំពុងតែរត់គេចពីរបបខ្មែរក្រហម។ នាងខ្ញុំយល់ថា វេទិកានេះល្អ និងបានបង្រៀនសិស្សពីប្រវត្តិសាស្ត្រខ្មែរចន្លោះពីឆ្នាំ១៩៧៥-១៩៧៩។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់វេទិកានេះ ដែលធ្វើឲ្យនាងខ្ញុំយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

ខ្ញុំឈ្មោះ **អន សុភ័ក** ភេទប្រុស អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ ក្រាំងស្វាយ។ ខ្ញុំបានទទួលបានចំណេះដឹងច្រើនពីរបបខ្មែរក្រហម ដែលមានការគៀបសង្កត់ការគំរាមកំហែង មកលើប្រជាជន។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនខ្មែរធ្វើការហួសកម្លាំង រួមមាន

ដឹកប្រឡាយ ធ្វើស្រែដោយគ្មានពេលឈប់សម្រាក និងមិនមានអាហារហូបចុកគ្រប់គ្រាន់។ ខ្មែរក្រហមដាក់ផែនការកំណត់ឲ្យប្រជាជនធ្វើស្រែក្នុងមួយហិកតាឲ្យបានបីតោន។ តាយាយរបស់ខ្ញុំធ្លាប់ ឆ្លងកាត់របបខ្មែរក្រហមបាននិយាយថា នៅក្នុងរបបនោះពេលយើងជួបសាច់ញាតិ បងប្អូន គឺយើងធ្វើមិនស្គាល់គ្នា។ ខ្មែរក្រហមបានធ្វើបាប និងដេញបាញ់គាត់ ប៉ុន្តែគាត់មានសំណាងរត់រួចខ្លួន។ តាមដែលខ្ញុំបានរៀន និងបានស្តាប់តាយាយនិយាយប្រាប់គឺដូចវេទិកាថ្ងៃនេះ។





នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ សិស្សានុសិស្ស ចំនួន៤០នាក់មកពីវិទ្យាល័យក្រាំងស្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ មកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្សវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ

**សួត វិចិត្រ**



នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្សានុសិស្ស ចំនួន៣៧ នាក់ មកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ការរើសអើង និងអំពើហិង្សា គឺជាមូលហេតុដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។ យោងតាមសៀវភៅដែលមានចំណងជើងថា «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក» ដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងអំពីប្រទេសចំនួន៥ដែលធ្លាប់កើតមានអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល ដោយក្នុងនោះក៏រួមបញ្ចូលនូវប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ របបកម្ពុជាប្រជាធិបតេយ្យ បានបន្សល់ទុកនូវសោកនាដកម្មនៃការស្លាប់បាត់បង់ជីវិតមនុស្សប្រមាណជិត២លាននាក់ ដោយសារការខ្វះអាហារ ការធ្វើការងារហួសកម្លាំង និងការសម្លាប់។

ផ្អែកលើសារសំខាន់នៃប្រវត្តិសាស្ត្រមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដោយមានការចូលរួមពីសិស្សានុសិស្សវិទ្យាល័យតេជោ

ហ៊ុន សែន ត្រពាំងតាវ ចំនួន៣៧ នាក់ ក្នុងគោលបំណងអប់រំដល់យុវជនពីអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានដឹកនាំការពិភាក្សាក្នុងវេទិកាថ្នាក់រៀន និងបានធ្វើបទបង្ហាញដោយលើកឡើងអំពីកំណត់ហេតុប្រចាំថ្ងៃរបស់គ្រូបង្រៀនបឋមសិក្សាឈ្មោះ ប៉ូច យូនលី ដែលបានកត់ត្រាអំពីជីវិតរស់នៅប្រចាំថ្ងៃ និងព្រឹត្តិការណ៍ផ្សេងៗអំឡុងពេលខ្លួនចូលទៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហម កាលពីឆ្នាំ១៩៧៣។

សេចក្តីសន្និដ្ឋានចុងក្រោយរបស់ ប៉ូច យូនលី បន្ទាប់ពីបានទៅដល់តំបន់នោះ គឺក្រុមកុម្មុយនីស្តខ្មែរក្រហមមិនងាយស្រួលនោះទេ ប៉ុន្តែកំឡុងពេលនោះ មនុស្សភាគច្រើនមិនសូវជឿទៅលើការលើកឡើងរបស់គាត់។ រហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានាទៅកាន់ទីជនបទដាច់ស្រយ៉ាលដើម្បីធ្វើកសិកម្ម។ ខ្មែរក្រហមបានបែងចែកប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ឬប្រជាជន១៧ មេសា ចាប់តាំងពីពេលនោះ ហើយខ្មែរក្រហមបានដាក់គោលនយោបាយបោសសម្អាតអ្នកណាក៏ដោយឲ្យតែជាប់ពាក់ព័ន្ធ សេរីស្រឡាយវៀតណាម និងអ្នកមានប្រវត្តិមិនស្អាតស្អំ។ នៅក្នុងផ្នែកនេះសិស្សានុ-សិស្សបានចោទជាសំណួរសំខាន់ៗដូចតទៅ ៖ ១) ហេតុអ្វីខ្មែរក្រហមប្រើមនោគមន៍វិជ្ជាបញ្ចុះបញ្ចូលប្រជាជនឲ្យលង់ជឿ បន្ទាប់មកបានកាប់សម្លាប់ជាតិសាសន៍ឯងមិនញញើតដៃ? ២) ហេតុអ្វីបានជាខ្មែរក្រហមបែងចែកវណ្ណៈប្រជាជន? ៣) ហេតុអ្វីមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ? ៤) តើមូលហេតុអ្វីដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ហើយផ្តល់ផលលំបាកអ្វីខ្លះ? ៥) តើការសម្លាប់មនុស្សនៅសម័យខ្មែរក្រហមមានទោសដែរឬទេ?

បន្ទាប់មកសិស្សានុសិស្សត្រូវបានបែងចែកជា ៤ ក្រុមផ្សេងៗគ្នា ដើម្បីអាននិងកត់ត្រាចំណុចសំខាន់ៗនៅក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅពេលទ្រង់យាងមកកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជាកាលពីឆ្នាំ១៩៧៣ និងខ្សែភាពយន្តឯកសារអំពី «តំបន់រំដោះឆ្នាំ១៩៧៣» ដើម្បីសិក្សារៀនសូត្រចេញពីការសង្ខេប និងការយល់ឃើញរបស់ក្រុមនីមួយៗ។ ឯកសារខាងលើនេះ បានបង្ហាញពីព្រឹត្តិការណ៍ដ៏សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់តាំងពីរដ្ឋប្រហាររបស់សេនាប្រមុខ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងដំណាក់កាលបន្ទាប់មកទៀត មុនពេលចលនាកុម្មុយនីស្តខ្មែរក្រហមក្តោបក្តាប់អំណាចបានទាំងស្រុងក្នុងប្រទេសកម្ពុជា។ ខណៈនោះ សិស្សានុសិស្សបានចោទសួរថា តើរបបខ្មែរក្រហមមានស្តេចគង់នៅដែរឬទេ? យោងតាមសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩)» បានសរសេរថា រដ្ឋសភារបស់ខ្មែរក្រហម មានប្រជុំតែម្តងគត់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺនៅពេលដែលខ្លួនបានជំរុញឲ្យសម្តេចព្រះ នរោត្តម សីហនុ លាលែងពីតំណែងជាព្រះប្រមុខរដ្ឋ របបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៦។ បន្ទាប់មក ខៀវ សំផន ដែលជាមេដឹកជាន់ខ្ពស់ និងទទួលខុសត្រូវខ្ពស់បំផុតក្នុងរបប



នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្សានុសិស្ស ចំនួន៣៧ នាក់ មកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្ពុជាប្រជាធិបតេយ្យ ដែលបច្ចុប្បន្នកំពុងជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទង្វើអមនុស្សធម៌ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បានឡើងកាន់តំណែងនោះជំនួសវិញនៅពេលនោះ។

នៅផ្នែកចុងក្រោយនៃវេទិកាថ្នាក់រៀន បណ្ឌិត លី សុខឃាង បានលើកឡើងអំពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត ដោយក្នុងនាមជាយុវជនម្នាក់ៗអាចចូលរួមនៅក្នុងសង្គម ដើម្បីកុំឲ្យរបបនេះវិលត្រឡប់មកវិញម្តងទៀត។ សិស្សានុសិស្សមួយចំនួនយល់ឃើញថា ការរៀនអំពីប្រវត្តិសាស្ត្រ និងការផ្សព្វផ្សាយ គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ក្នុងពេលដែលអ្នកផ្សេងទៀតយល់ថា ការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ សហគមន៍ និងសង្គម, ការដោះស្រាយជម្លោះដោយសន្តិវិធី, ការការពារសិទ្ធិជាបុគ្គល និងការលុបបំបាត់ការរើសអើង ក៏ជាវិធីសាស្ត្រមួយក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែរ។



នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្សានុសិស្ស ចំនួន៣៧ នាក់ មកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀនស្តីអំពីសារសំខាន់នៃការសិក្សា

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង អំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ផេង ពង្សរ៉ាស៊ី







*នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀន ស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង អំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សម្រាប់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ព្រៃញ្ញោ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំវេទិកាថ្នាក់រៀន ស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង អំណានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សម្រាប់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ព្រៃញ្ញោ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង។ វេទិកាថ្នាក់រៀននេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សិស្សអំពីមាតិកាប្រវត្តិសាស្ត្រ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍។ បន្ថែមលើវត្ថុបំណងនៃវេទិកាថ្នាក់រៀននេះ គឺការឈ្វេងយល់បន្ថែមអំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលបានកើតឡើងនៅចន្លោះចុងខែកុម្ភៈ ដល់ចុងខែមីនា ឆ្នាំ១៩៧៣ ដែលជាព្រឹត្តិការណ៍នៃការយាងមកកាន់ប្រទេសកម្ពុជារបស់សម្តេច

ព្រះ នរោត្តម សីហនុ និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ដើម្បីស្វែងរកសុខសន្តិភាព ជូនប្រជាជាតិខ្មែរ។ វគ្គបំណងទាំងអស់ខាងលើនេះ គឺដើម្បីការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលបានកើតឡើងនៅចន្លោះពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

មុនពេលចាប់ផ្តើមវេទិកាថ្នាក់រៀននេះ សិស្សទាំងអស់ត្រូវបំពេញតារាងវាស់ស្ទង់ចំណេះដឹង បន្ទាប់មកក៏បង្កើតការពិភាក្សាអំពីចំណេះដឹងរបស់សិស្សទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងការយាងមកកាន់តំបន់រំដោះឆ្នាំ១៩៧៣ របស់សម្តេចព្រះ នរោត្តម សីហនុ និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ផ្តល់ឱកាសដល់សិស្សលើកឡើងពីចម្ងល់ផ្សេងៗទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមមកកាន់ លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។

បន្ទាប់ពីឆ្លើយតបទៅនឹងចម្ងល់របស់សិស្ស លោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញខ្លីស្តីអំពីមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហម ដោយសង្ខេបលើជំពូក «ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ របស់ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ» ដោយផ្តោតសំខាន់លើ ផលវិបាកក្រោយរដ្ឋប្រហារ, ការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា, ការកេងចំណេញពីការធ្វើរដ្ឋប្រហារដោយក្រុមខ្មែរក្រហម, ការកេងចំណេញពីការបង្កើតរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដោយក្រុមខ្មែរក្រហម, ការស្នើសុំយាងមកកាន់ប្រទេសកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ និងការបង្ហាញពីចេតនារបស់ក្រុមខ្មែរក្រហម ក្នុងការរារាំងដំណើរមកកាន់ប្រទេសកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ ដោយផ្អែកលើសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»៖ កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។

នៅចុងបញ្ចប់វេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» គឺសិស្សឡើងអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានចែកជូន។ បន្ទាប់មកក្រុមការងារក៏ផ្តល់តារាងវាស់ស្ទង់ចំណេះដឹងដល់សិស្សានុសិស្សក្រោយវេទិកាថ្នាក់រៀនដើម្បីបំពេញ ព្រមទាំងផ្តាំផ្ញើដល់សិស្សឲ្យអានសៀវភៅឲ្យបានច្រើនដើម្បីឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរ។



នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាថ្នាក់រៀន ស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងអំណានសៀវភៅ «សាក្សប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សម្រាប់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ព្រៃញ៉ោ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង ការចែក

## សៀវភៅ «សាក្សីប្រវត្តិសាស្រ្ត» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅក្នុងភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

**ធី គីមហុង**



នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំកម្មវិធីវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥៩១៩៧៩) និងការចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៥០ក្បាល ជូន តា យាយ អ៊ំពូមីង និង សិស្សានុសិស្សនៅក្នុងភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំកម្មវិធីវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៥០ក្បាលជូន តា យាយ អ៊ំពូមីង និងសិស្សានុសិស្ស រស់នៅក្នុងភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ជាកិច្ចចាប់ផ្តើមនៃវេទិកា លោក សៅ សុខ អាយុ ៦៦ឆ្នាំ តំណាងឲ្យប្រជាជនក្នុងភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ឡើងប្រកាសបើកកម្មវិធី និងថ្លែងអំណរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលចុះមក

ផ្សព្វផ្សាយអំពីរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហម និង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅថ្ងៃនេះ។

ជាកិច្ចបន្តលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានឡើងសម្តែងការអរគុណដល់លោកតា លោកយាយ អ៊ំពូមីង និងសិស្សានុសិស្សៗ ទាំងអស់ដែលបានចូលរួមក្នុងវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ឆ្លៀតឱកាសនោះ លោក ឡុង ដានី ក៏បានណែនាំខ្លួន និងក្រុមការងារ ព្រមទាំងជម្រាបពីចំណុចសំខាន់នៃការបង្កើតមជ្ឈមណ្ឌលផ្សះផ្សាវាលវែងឡើងក្នុងគោលបំណងដូចខាងក្រោម ៖

១) ផ្សព្វផ្សាយពីប្រវត្តិសាស្ត្រសង្គ្រាម និងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

២) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឲ្យចែករំលែកបទពិសោធន៍រស់នៅក្នុងរបបខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ។

៣) ពង្រឹងសន្តិភាពតាមរយៈការអប់រំ ដោយផ្តល់ឱកាសដល់យុវជនជំនាន់ក្រោយបានសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

៤) ធ្វើការចងក្រងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

៥) ជួយសម្របសម្រួលលើគម្រោង «លើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

ផ្សាភ្ជាប់ជាមួយការចែករំលែករឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកកាន់យុវជនជំនាន់ក្រោយ លោក ឡុង ដានី បានបែងចែកនិងបង្កើតការពិភាក្សាជាក្រុមក្នុងចំណោមអ្នកមកចូលរួមវេទិកាសហគមន៍ទាំងអស់ ដោយក្រុមនីមួយៗមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរៀបរាប់អំពីរឿងរ៉ាវដែលខ្លួនធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហមទៅកាន់សិស្សានុសិស្ស។ ចំណែកសិស្សានុសិស្សត្រូវស្តាប់ កត់ត្រា និងសង្ខេបរឿងរ៉ាវ ដើម្បីចែករំលែកទៅកាន់ក្រុមផ្សេងទៀត។ ខាងក្រោមនេះគឺជាការសង្ខេបរបស់ក្រុមនីមួយៗ៖

## ក្រុមទី១ ៖ សង្ខេបរឿងរ៉ាវរបស់ ជ័យ ឡាយ

កាលពីកុមារ ជ័យ ឡាយ មិនបានចូលរៀនទេ ដោយសារតែឆ្នាំ១៩៧០ ប្រទេសជាតិកើតមានសង្គ្រាម។ ឡាយ បានចូលធ្វើជាកងទ័ពខ្មែររំដោះនៅខេត្តតាកែវ។ ឡាយ ត្រូវឡើងទៅប្រយុទ្ធតទល់នឹងកងទ័ព លន់ នល់ នៅទីក្រុងភ្នំពេញ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានទទួលជ័យជម្នះលើរបប លន់ នល់ ពេលនោះ ឡាយ សប្បាយចិត្តខ្លាំងណាស់។ ក្រោយមក ឡាយ បានខកចិត្តដោយសារខ្មែរក្រហមបានបំបែកគាត់ពីគ្រួសារ។

## ក្រុមទី២៖ សង្ខេបរឿងរ៉ាវរបស់ ឆែល

នៅឆ្នាំ១៩៧៩ ឆែល បានរត់គេចខ្លួនចេញពីស្រុកដងទង់ ខេត្តកំពត ពីតាមការវាយប្រហាររបស់កងទ័ពវៀតណាម រហូតទៅដល់ខេត្តកោះកុង។ ប៉ុន្តែ ឆែល បានឈឺពោះសម្រាលកូននៅម្តុំស្ទឹងខៀវ។ នៅទីនោះ ប្តីរបស់ ឆែល បានលង់ទឹកស្លាប់។ ចំណែកកងទ័ពវៀតណាមនៅតែបន្តវាយរហូតដល់មេស្ទឹង។ ឆែល ឆ្លងពីមេស្ទឹងក៏បានជួបទាហានថៃ។ ទាហានថៃទាំងនោះបាននាំឆែលនៅស្នាក់នៅជំរំខៅ ឡាន ស្រុកខ្លងយៃ ខេត្តត្រាត ប្រទេសថៃ ហើយ ឆែល ក៏បានរស់រានមានជីវិតមកដល់សព្វថ្ងៃ។

## ក្រុមទី៣៖ សង្ខេបរឿងរ៉ាវរបស់ ឌុល រីម

ឌុល រីម ភេទស្រី អាយុ៦៨ឆ្នាំ។ នៅក្នុងរបបខ្មែរក្រហម ខ្មែរក្រហមប្រើ រីម ឲ្យរែកដី លើកទំនប់ កាត់ដើមទន្ទ្រានខែត្រ និងកាប់ដីដំបូក ដើម្បីលាយបញ្ចូលគ្នាធ្វើជីដាក់ស្រែ។ ខ្មែរក្រហម ប្រើ រីម ឲ្យធ្វើការងារច្រើន ប៉ុន្តែមិនបានផ្តល់របបអាហារឲ្យ រីម ហូបគ្រប់គ្រាន់ឡើយ។ ការហូបមិនឆ្អែតបានបណ្តាលឲ្យប្រជាជនមួយចំនួនបានស្លាប់។

ក្រោយចប់កម្មវិធីពិភាក្សា សិស្សានុសិស្ស និងអ្នកចូលរួមបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

**ផាត រក្សា** គឺជាសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ រៀបរាប់ថា ខ្ញុំពិតជារីករាយខ្លាំងណាស់ដែលបានមកចូលរួមក្នុងវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងបានស្តាប់រឿងរ៉ាវរបស់តាយាយដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម នៅក្នុងភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

**សៅ សុខ** គឺជាប្រជាជនមានប្រសាសន៍ថា ខ្ញុំគិតថា កម្មវិធីនេះមានប្រយោជន៍ខ្លាំងណាស់សម្រាប់ការស្រាវជ្រាវប្រវត្តិសាស្ត្រជាតិខ្មែរ ជាពិសេសក្មេងៗជំនាន់ក្រោយមួយចំនួនដែលមិនជឿលើការរៀបរាប់របស់ឪពុកម្តាយអំពីរបបខ្មែរក្រហម។ ខ្ញុំសូមជូនពរក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បងប្អូន តា យាយ និងក្មួយៗទាំងអស់ឲ្យជួបតែសំណាងល្អ។

ចុងក្រោយនៃវេទិកាអប់រំសហគមន៍លោក ឡុង ដានី បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលរៀបរាប់អំពីព្រះរាជដំណើរអមសម្តេចព្រះ នរោត្តម សីហនុយាងចេញទីក្រុងប៉េកាំងប្រទេសចិនមកទីក្រុងហាណូយប្រទេសវៀតណាម និងបន្តដំណើរឆ្ពោះមកកាន់តំបន់រំដោះប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ ជូនសិស្សានុសិស្ស និងអ្នកចូលរួមដើម្បីសិក្សាឈ្វេងយល់ពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាបន្ថែមទៀត។





*នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំកម្មវិធីវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៥០ក្បាល ជូន តាយាយ អ៊ំពូមីង និងសិស្សានុសិស្សនៅក្នុង ភូមិទំព័រ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# អាន គុម ៖ ខ្ញុំបាត់បង់បងប្រុសម្នាក់ ក្នុងរបបខ្មែរក្រហម

ផន ចន្ធី

ខ្ញុំឈ្មោះ អាន គុម កើតនៅឆ្នាំ១៩៤៧ ភូមិស្រែជា ឃុំសំឡាញ់ ស្រុកអង្គរជ័យ ខេត្តកំពត។ សព្វថ្ងៃខ្ញុំរស់នៅភូមិបាក់នឹម ឃុំព្រេស ស្រុកជុំគិរី ខេត្តកំពត។ កាលពីវ័យកុមារ ខ្ញុំមិនបានរៀនសូត្រទេ ដោយសារជីវភាពគ្រួសារខ្វះខាត។ ខ្ញុំត្រូវនៅផ្ទះជួយការងារស្រែចម្ការឪពុកម្តាយរហូតដល់វ័យជំទង់ទើបបានចូលរៀនអក្ខរកម្មរយៈពេលមួយឆ្នាំ ប៉ុន្តែខ្ញុំមិនចេះអក្សរនោះទេ។ លុះមកដល់ឆ្នាំ១៩៧០ ខ្ញុំបានរៀបការ និងចាកចេញពីឪពុកម្តាយទៅបង្កើតក្រុមគ្រួសារមួយ ដោយប្រកបមុខរបរធ្វើស្រែចម្ការ និងបានផ្លាស់ទីលំនៅមករស់នៅភូមិដានគោម ខាងត្បូង ឃុំដានគោម ស្រុកអង្គរជ័យ ខេត្តកំពត ជាមួយប្តី។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុភ្លាម ក៏មានការដាក់ពង្រាយកងកម្លាំងធីវគីនៅភូមិស្រែជា និងភូមិដានគោមខាងត្បូង។ បន្ទាប់ពីខ្ញុំរៀបការបានរយៈពេលបីខែ ខ្ញុំក៏មានផ្ទៃពោះ។ នៅរដូវវស្សា គ្រួសាររបស់ខ្ញុំបានភ្ជួររាស់សាបព្រួស ចំណែកខ្ញុំដើរស៊ីឈ្នួលដកសំណាបដើម្បីបានប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារដែលកំពុងមានការខ្វះខាត។

ថ្ងៃមួយ ពេលខ្ញុំកំពុងដកសំណាបនៅវាលស្រែ ស្រាប់តែឮសន្ធឹកម៉ាស៊ីន ខ្ញុំក៏ងើបមុខឡើង និង សម្លឹងរកមើលប្រភពសំឡេង ក៏ឃើញរថក្រោះចំនួន៧គ្រឿង បើកចេញពីភ្នំសែនហាន ឆ្ពោះមកកាន់ភូមិរបស់ខ្ញុំ។ បន្ទាប់មក ក៏មានការប្រយុទ្ធគ្នាយ៉ាងខ្លាំង ដោយមានគ្រាប់



អាន គុម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្លោងចេញពីរថក្រោះទាហានធីវគី។ ខ្ញុំនិងអ្នកភូមិនាំគ្នារត់គេចខ្លួនទៅដល់ភ្នំមួយ ដែលអ្នកភូមិហៅថាតំបន់ភ្នំក្រោល។ យើងនាំគ្នាពួនសម្ងំលាក់ខ្លួននៅទីនោះបណ្តោះអាសន្នរហូតដល់ការប្រយុទ្ធគ្នាមានសភាពស្ងប់ស្ងាត់ទើបយើងត្រឡប់ចូលក្នុងភូមិវិញ។ នៅវេលាថ្ងៃត្រង់ថ្ងៃមួយ ខ្ញុំកំពុងដួតទឹកពាងនៅខាងក្រោយផ្ទះ ស្រាប់តែឮសំឡេងម៉ាស៊ីនម្តងទៀត ពេលខ្ញុំក្រឡេកទៅលើឃើញយន្តហោះជាច្រើនគ្រឿង ហោះឆ្វេលពីលើភូមិ និងទម្លាក់គ្រាប់ចុះមក។ ខ្ញុំមិនដឹងថាសង្គ្រាមរាលដាលមកដល់ភូមិចាប់តាំងពីពេលណានោះទេ។ ខ្ញុំ និងគ្រួសារនាំគ្នារត់ទៅពួនក្នុងរណ្តៅត្រង់សេ (លេណដ្ឋាន) ចំនួន៧ ដែលយើងបានជីកទុករួចជាស្រេចនៅជុំវិញផ្ទះ។

បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ និងគ្រប់គ្រងភូមិដំបូង ខ្មែរក្រហមបានចាត់ខ្ញុំឲ្យទៅផលិតជី, បាចទឹក, ដកស្ទូង, ប្រមូលស្រូវជាក្រុមនៅភូមិអង្គខ្លាយ និងនៅតាមទីកន្លែងផ្សេងៗទៀត។ ចំណែកកងកិនអង្ករស្ថិតនៅភូមិពន្លៃ និងកងធ្វើចម្ការ គឺនៅតំបន់ភ្នំត្រាំងត្រែង។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចទាំងស្រុងនៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅរស់នៅភូមិ០៥ ឃុំព្រៃយុតថ្កា ស្រុកកោះអណ្តែត ខេត្តតាកែវ ដើម្បីធ្វើស្រែក្នុងមួយឆ្នាំពងង។

នៅចុងឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានវាយដណ្តើមកាន់កាប់ស្រុកកោះអណ្តែតទាំងស្រុង។ ពេលនោះ ខ្មែរក្រហមបានបញ្ជូនខ្ញុំមករស់នៅភូមិយល់ចេក ឃុំក្រាំងស្បែក ស្រុកទ្រាំង ខេត្តតាកែវ ដោយចាត់ខ្ញុំឲ្យធ្វើការងារនៅតាមកងនារី។ ចំពោះរបបអាហារខ្ញុំទទួលបានបបរ ប្រសិនបើធ្វើការមិនរួចរាល់តាមផែនការ ខ្មែរក្រហមមិនចែករបបអាហារឲ្យឡើយ ថែមទាំងដាក់ការងារបន្ថែមឲ្យខ្ញុំទៀត។ មានពេលមួយ ដោយសារអត់ទ្រាំនឹងភាពលំបាកមិនបាន ខ្ញុំលួចរត់គេចចេញពីកង ប៉ុន្តែខ្ញុំគេចមិនរួចក៏ត្រូវអង្គការចាប់បាននឹងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ ក្រោយមក ខ្ញុំលួចរត់គេចមកស្រុកកំណើតម្តងទៀត ក្នុងចម្ងាយផ្លូវ៧០គីឡូម៉ែត្រ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងប្រុសម្នាក់ ដោយខ្មែរក្រហមចាប់ចងស្លាបសេកយកទៅសម្លាប់ចោល ព្រោះគាត់គឺជាអតីតទាហាន លន់ នល់។

រូបក្របមុខ៖
កងទ័ពបដិវត្តន៍ខ្មែរក្រហមខ្មែរតំបន់រំដោះ នៅខេត្តសៀម ក្នុងឆ្នាំ១៩៧៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
កងទ័ពបដិវត្តន៍ខ្មែរក្រហម កំពុងលើកប្រពន្ធភ្លឺស្រែ នៅតំបន់រំដោះ នៅក្នុងឆ្នាំ១៩៧៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣
DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110
Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 286, October 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.